- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧៥.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម។

មាត្រា២._

អនុក្រឹត្យនេះ មានគោលបំណងដូចខាងក្រោម ÷

- រៀបចំបេសកកម្មនិងរចនាសម្ព័ន្ធរបស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- រៀបចំមុខងារនិងភារកិច្ចរបស់អង្គភាពនានានៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- ធានាគុណភាពនិងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារ ក្នុងវិស័យឧស្សាហកម្មនិងសិប្បកម្ម។

**មាត្រា៣._**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់អង្គភាពនៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម ទាំងនៅថ្នាក់កណ្ដាល និងនៅថ្នាក់មូលដ្ឋាន ដោយគ្របដណ្ដប់លើវិស័យឧស្សាហកម្មនិងសិប្បកម្ម នៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## បេសកកម្មនិងរចនាសម្ព័ន្ធ

**មាត្រា៤._**

ក្រសួងឧស្សាហកម្មនិងសិប្បកម្មបំពេញមុខងារជាសេនាធិការឱ្យរាជរដ្ឋាភិបាល លើបេសកកម្មដឹកនាំនិងគ្រប់គ្រងវិស័យឧស្សាហកម្មនិងសិប្បកម្មនៃព្រះរាជាណាចក្រកម្ពុជា។

បេសកកម្មនេះ ត្រូវធ្វើឡើងតាមរយៈការរៀបចំនិងការអនុវត្តឱ្យបានត្រឹមត្រូវនូវគោលនយោបាយ ក្របខណ្ឌច្បាប់ និងបទបញ្ញាទាំងឡាយ ដែលទាក់ទងនឹងការដឹកនាំនិងការគ្រប់គ្រងវិស័យឧស្សាហកម្មនិងសិប្បកម្ម។

**មាត្រា៥._**

ក្រសួងឧស្សាហកម្មនិងសិប្បកម្ម មានមុខងារនិងភារកិច្ច ដូចតទៅ÷

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ទិសដៅ និងផែនការរួមរបស់រាជរដ្ឋាភិបាល ក្នុងវិស័យឧស្សាហកម្មនិងសិប្បកម្ម
- អនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ទិសដៅ និងផែនការអភិវឌ្ឍន៍ក្នុងវិស័យឧស្សាហកម្មនិងសិប្បកម្ម
- ដឹកនាំនិងគ្រប់គ្រងវិស័យឧស្សាហកម្មនិងសិប្បកម្ម នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- រៀបចំគោលនយោបាយនិងកម្មវិធីអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម
- អនុវត្តការងារសិក្សាស្រាវជ្រាវ ពិសោធន៍ និងអភិវឌ្ឍបច្ចេកវិទ្យាវិទ្យាសាស្ត្រដើម្បីគាំទ្រ និងជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មនិងសិប្បកម្ម
- ជំរុញនិងគាំទ្រនវានុវត្តន៍បច្ចេកវិទ្យា តក្កកម្ម គ្រប់គំនិតផ្ដួចផ្ដើមថ្មីៗ រួមទាំងសហគ្រិនភាពក្នុងវិស័យឧស្សាហកម្មនិងសិប្បកម្ម
- គ្រប់គ្រង វាយតម្លៃ ទទួលស្គាល់ និងផ្ដល់វិញ្ញាបនបត្រ ប្រកាសនីយបត្រ លើតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម
- រៀបចំ គ្រប់គ្រង និងផ្សព្វផ្សាយបច្ចេកវិទ្យា

- រៀបចំ គ្រប់គ្រង និងផ្សព្វផ្សាយការងារស្តង់ដារូបនីយកម្ម និងការធានាគុណភាពផលិតផល
- ធ្វើជាអាណាព្យាបាលបច្ចេកទេសលើសហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលត្រូវបានបង្កើតឡើងនៅក្នុងវិស័យឧស្សាហកម្មនិងសិប្បកម្ម
- រៀបចំគ្រប់គ្រង ផ្សព្វផ្សាយ ការងារមាត្រាសាស្ត្រ
- រៀបចំគ្រប់គ្រង និងអនុវត្តនយោបាយ ផ្គត់ផ្គង់ទឹកស្អាតដល់ទីក្រុង និងទីប្រជុំជន
- សហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងតំបន់ ស្ថាប័ន អង្គការជាតិនិងអន្តរជាតិនានា ដើម្បីជំរុញអភិវឌ្ឍន៍វិស័យឧស្សាហកម្មនិងសិប្បកម្ម។

**មាត្រា៦.-**

ក្រសួងឧស្សាហកម្មនិងសិប្បកម្ម មានរចនាសម្ព័ន្ធដូចខាងក្រោម÷

**ក-អង្គភាពថ្នាក់កណ្តាល**

១-ខុទ្ទកាល័យរដ្ឋមន្ត្រី

២-អគ្គនាយកដ្ឋានកិច្ចការទូទៅ

៣-អគ្គនាយកដ្ឋានឧស្សាហកម្ម

៤-អគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម

៥-វិទ្យាស្ថានស្តង់ដារកម្ពុជា

៦-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

៧-អគ្គាធិការដ្ឋាន

៨-នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**ខ-អង្គភាពថ្នាក់មូលដ្ឋាន**

នៅថ្នាក់មូលដ្ឋាន មានមន្ទីរឧស្សាហកម្មនិងសិប្បកម្ម និងសាខាសមត្ថកិច្ចជំនាញ រាជធានី ខេត្ត។

**មាត្រា៧.-**

អគ្គនាយកដ្ឋាន ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួន ជាជំនួយការ។

វិទ្យាស្ថាន និងមជ្ឈមណ្ឌល ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអគ្គនាយក និងអមដោយអនុប្រធានមួយចំនួន ឋានៈស្មើអគ្គនាយករង ជាជំនួយការ។

អគ្គាធិការដ្ឋាន ដឹកនាំដោយអគ្គាធិការមួយរូប មានឋានៈស្មើអគ្គនាយក និងអមដោយអគ្គាធិការរងមួយចំនួន ឋានៈស្មើអគ្គនាយករង ជាជំនួយការ។

នាយកដ្ឋាន ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ជាជំនួយការ។

អង្គភាពថ្នាក់មូលដ្ឋាននៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ដែលមានឋានៈចាប់ពីអនុប្រធាននាយកដ្ឋានចុះ។

អង្គការលេខរបស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៨.-**

ការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពនានា ក្រោមឱវាទរបស់អគ្គនាយកដ្ឋាន វិទ្យាស្ថាន មជ្ឈមណ្ឌល អគ្គាធិការដ្ឋាន និងអង្គភាពថ្នាក់មូលដ្ឋាននៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម។

## ជំពូកទី៣

## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា៩.-**

ខុទ្ទកាល័យរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់តាមបទប្បញ្ញត្តិនៃអនុក្រឹត្យ លេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន។

## ជំពូកទី៤

## អគ្គនាយកដ្ឋានកិច្ចការទូទៅ

**មាត្រា១០.-**

អគ្គនាយកដ្ឋានកិច្ចការទូទៅបំពេញមុខងារជាសេនាធិការឱ្យក្រសួងឧស្សាហកម្មនិងសិប្បកម្ម ដោយមានភារកិច្ច ដូចតទៅ÷

- គ្រប់គ្រងការងាររដ្ឋបាល និងសម្របសម្រួលសកម្មភាពគ្រប់ផ្នែក របស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងអង្គភាពថ្នាក់កណ្តាលនិងអង្គភាពថ្នាក់មូលដ្ឋានក្រោមឱវាទ និងអង្គភាពដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស
- រៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ជួយសម្រួលដល់ការងារគ្រប់គ្រងរបស់ក្រសួងទាំងថ្នាក់កណ្តាល និងនៅអង្គភាពមូលដ្ឋាន
- គ្រប់គ្រងយានដ្ឋាន និងយានយន្ត របស់រដ្ឋដែលប្រគល់ជូនក្រសួង ព្រមទាំងធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ធនៈ និងគ្រឿងបន្លាស់
- ទទួលនិងបែងចែកសម្ភារៈបរិក្ខារ ជូនដល់បណ្តាអង្គភាពថ្នាក់មូលដ្ឋាន
- គ្រប់គ្រងមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈមិនមែនមន្ត្រីរាជការ របស់ក្រសួងដោយទំនាក់ទំនងជាមួយក្រសួងមុខងារសាធារណៈ និងវាយតម្លៃសេចក្តីត្រូវការក្នុងការបណ្តុះបណ្តាល
- រៀបចំការងារបៀវត្សពលកម្ម ប្រាក់កម្រៃ និងរបបឧបត្ថម្ភសន្តិសុខសង្គម
- រៀបចំនិងអនុវត្តគោលនយោបាយបណ្តុះបណ្តាលដំបូងនិងបន្ត ដោយទំនាក់ទំនងជាមួយក្រសួងមុខងារសាធារណៈ និង/ឬធ្វើការអភិវឌ្ឍន៍ធនធានមនុស្ស ដោយសហការជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ
- លើកគម្រោងថវិកាក្រសួង និងតាមដានរំលឹកអំពីការអនុវត្តថវិកា

- ប្រមូលផ្តុំគ្រប់គ្រង និងសម្របសម្រួល រាល់ការចំណាយរបស់ក្រសួងទៅតាមខ្ទង់ជំពូកថវិកា រួមទាំងការងារលទ្ធកម្មសាធារណៈ
- ប្រមូលចំណូលឱ្យបានសមស្របតាមច្បាប់ហិរញ្ញវត្ថុ ដែលបានកំណត់
- ប្រមូលផ្តុំសេចក្តីត្រូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំជួសជុលសម្ភារៈ និងបរិក្ខាររបស់ក្រសួង
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- រៀបចំតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យឧស្សាហកម្មនិងសិប្បកម្ម
- ស្រាវជ្រាវ ដកស្រង់ ចងក្រង និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនិងសន្ធិសញ្ញាអន្តរជាតិ ពាក់ព័ន្ធវិស័យឧស្សាហកម្មនិងសិប្បកម្ម
- ណែនាំ និងតាមដានការអនុវត្តលិខិតបទដ្ឋានគតិយុត្តនិងសន្ធិសញ្ញាអន្តរជាតិ ក្នុងវិស័យឧស្សាហកម្មនិងសិប្បកម្ម
- ជំនួយការច្បាប់ផ្នែកឧស្សាហកម្មនិងសិប្បកម្ម សម្រាប់ថ្នាក់ដឹកនាំក្រសួង និងបណ្តាអង្គភាព ក្រោមឱវាទ និងអង្គភាពក្រោមអាណាព្យាបាលបច្ចេកទេស របស់ក្រសួង
- ដោះស្រាយវិវាទ និងទទួលបន្ទុកការងារពាក់ព័ន្ធតុលាការក្នុងសមត្ថកិច្ចក្រសួង
- រៀបចំផែនការ និងតាមដានការអនុវត្តផែនការសហប្រតិបត្តិការទ្វេភាគី ពហុភាគីជាមួយស្ថាប័នអន្តរជាតិនិងអាស៊ាន ពាក់ព័ន្ធវិស័យឧស្សាហកម្មនិងសិប្បកម្ម ដោយសហការជាមួយអង្គភាពជំនាញ នៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួង ស្ថាប័នពាក់ព័ន្ធ និងជាមួយលេខាធិការដ្ឋានអាស៊ាន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**មាត្រា១១.-**

អគ្គនាយកដ្ឋានកិច្ចការទូទៅ មាននាយកដ្ឋានក្រោមឱវាទចំនួន ៥ ដូចខាងក្រោម÷

-នាយកដ្ឋានរដ្ឋបាល

-នាយកដ្ឋានបុគ្គលិក

-នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ

-នាយកដ្ឋាននីតិកម្ម

-នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការនិងការងារអាស៊ាន។

អគ្គនាយកដ្ឋានកិច្ចការទូទៅ ទទួលបន្ទុកសម្របសម្រួលមន្ទីរឧស្សាហកម្មនិងសិប្បកម្មរាជធានី ខេត្ត ដែលតំណាងឱ្យក្រសួងឧស្សាហកម្មនិងសិប្បកម្ម នៅថ្នាក់មូលដ្ឋាន។

**មាត្រា១២.-**

នាយកដ្ឋានរដ្ឋបាល បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅ លើការងាររដ្ឋបាល។

នាយកដ្ឋានបុគ្គលិក បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅ លើការងារបុគ្គលិក។

នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅ លើការងារគណនេយ្យនិងហិរញ្ញវត្ថុ។

នាយកដ្ឋាននីតិកម្ម បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅ លើការងារនីតិកម្ម។

នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការនិងការងារអាស៊ាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅ លើការងារផែនការ ស្ថិតិ សហប្រតិបត្តិការនិងការងារអាស៊ាន។

## ជំពូកទី៥

## អគ្គនាយកដ្ឋានឧស្សាហកម្ម

**មាត្រា១៣.-**

អគ្គនាយកដ្ឋានឧស្សាហកម្ម បំពេញមុខងារជាសេនាធិការឱ្យក្រសួងឧស្សាហកម្មនិងសិប្បកម្ម លើការងារឧស្សាហកម្ម ដោយមានភារកិច្ចដូចតទៅ ÷

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ទិសដៅ និងផែនការរួមក្នុងវិស័យឧស្សាហកម្ម
- រៀបចំ គ្រប់គ្រង ផ្សព្វផ្សាយ និងអភិវឌ្ឍន៍ឧស្សាហកម្ម
- ជំរុញនិងគាំទ្រនវានុវត្តន៍បច្ចេកវិទ្យា តក្កកម្ម គ្រប់គំនិតផ្តួចផ្តើមថ្មីៗ ក្នុងវិស័យឧស្សាហកម្ម
- រៀបចំ គ្រប់គ្រង និងផ្សព្វផ្សាយការងារស្តង់ដារ បច្ចេកវិទ្យា
- គ្រប់គ្រង និងអនុវត្តការវាយតម្លៃទទួលស្គាល់
- ត្រួតពិនិត្យ វាយតម្លៃទទួលស្គាល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម
- អនុវត្តគោលនយោបាយនិងផែនការក្នុងការការពារសិទ្ធិលើកម្មសិទ្ធិឧស្សាហកម្ម
- គ្រប់គ្រង វាយតម្លៃ និងទទួលស្គាល់ តក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម
- រៀបចំ គ្រប់គ្រង និងអភិវឌ្ឍផលិតកម្ម អាជីវកម្ម និងបណ្តាញចែកចាយទឹកស្អាត
- គ្រប់គ្រង សម្របសម្រួល និងជំរុញចលនានិងការអភិវឌ្ឍផលិតភាព នៅកម្ពុជា
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**មាត្រា១៤.-**

អគ្គនាយកដ្ឋានឧស្សាហកម្ម មានរចនាសម្ព័ន្ធដូចខាងក្រោម÷

- នាយកដ្ឋានកិច្ចការឧស្សាហកម្ម
- នាយកដ្ឋានបច្ចេកទេស វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- នាយកដ្ឋានទឹកស្អាត
- នាយកដ្ឋានវាយតម្លៃទទួលស្គាល់
- នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម
- មជ្ឈមណ្ឌលផលិតភាពជាតិ។

**មាត្រា១៥.–**

នាយកដ្ឋានកិច្ចការឧស្សាហកម្ម បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានឧស្សាហកម្ម លើកិច្ចការឧស្សាហកម្ម។

នាយកដ្ឋានបច្ចេកទេសវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានឧស្សាហកម្ម លើការងារបច្ចេកទេសវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ។

នាយកដ្ឋានទឹកស្អាត បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានឧស្សាហកម្ម លើការងារទឹកស្អាត។

នាយកដ្ឋានវាយតម្លៃទទួលស្គាល់ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានឧស្សាហកម្ម លើការងារវាយតម្លៃទទួលស្គាល់ លើអង្គភាពវាយតម្លៃភាពអនុលោម។

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានឧស្សាហកម្ម លើការងារកម្មសិទ្ធិឧស្សាហកម្ម។

មជ្ឈមណ្ឌលផលិតភាពជាតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានឧស្សាហកម្ម លើការងារផលិតភាពជាតិ។

## ជំពូកទី៦

## អគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម

**មាត្រា១៦.–**

អគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម បំពេញមុខងារជាសេនាធិការឱ្យក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការងារសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ដោយមានភារកិច្ចដូចតទៅ ÷

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ទិសដៅ និងផែនការរួមលើវិស័យសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម
- រៀបចំ គ្រប់គ្រង ផ្សព្វផ្សាយ និងអភិវឌ្ឍវិស័យសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម
- គាំទ្រនិងលើកស្ទួយសហគ្រិនភាព ក្នុងវិស័យសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម
- សហប្រតិបត្តិការជាមួយបណ្ដាប្រទេស ស្ថាប័ន អង្គការជាតិ និងអន្តរជាតិនានា ដើម្បីជំរុញអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម
- ពិនិត្យ វាយតម្លៃ និងអនុម័តលើគម្រោងវិនិយោគឯកជន លើសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ដោយផ្ទាល់ ឬដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ
- ចុះបញ្ជីគ្រប់គ្រង និងត្រួតពិនិត្យសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម
- លើកសំណើ សម្របសម្រួល និងពិនិត្យតាមដានការអនុវត្តវិនិយោគសាធារណៈ ក្នុងវិស័យសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម
- រៀបចំ ប្រកាសអនុញ្ញាតឱ្យសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ដំណើរការ

- វាយតម្លៃលើយថាប្រភេទ និងបរិមាណវត្ថុធាតុដើមប្រើប្រាស់របស់សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម តាមបទដ្ឋានបច្ចេកទេស
- រៀបចំបញ្ជីផលិតផលនៃសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម
- ផ្តល់លិខិតបញ្ជាក់នានា ដែលពាក់ព័ន្ធដល់ផលិតកម្មរបស់សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**មាត្រា១៧.-**

អគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យមនិងសិប្បកម្ម មាននាយកដ្ឋានក្រោមឱវាទចំនួន ៣ ដូចតទៅ÷

- នាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម
- នាយកដ្ឋានកិច្ចការសិប្បកម្ម
- នាយកដ្ឋានផែនការ និងជំរុញការអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម។

**មាត្រា១៨.-**

នាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម លើការងារសហគ្រាសធុនតូចនិងមធ្យម។

នាយកដ្ឋានកិច្ចការសិប្បកម្ម បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម លើកិច្ចការសិប្បកម្ម។

នាយកដ្ឋានផែនការ និងជំរុញការអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម លើការងារផែនការ និងជំរុញដល់កិច្ចអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម។

## ជំពូកទី៧
## វិទ្យាស្ថានស្តង់ដារកម្ពុជា

**មាត្រា១៩.-**

វិទ្យាស្ថានស្តង់ដារកម្ពុជា បំពេញមុខងារជាសេនាធិការឱ្យក្រសួងឧស្សាហកម្មនិងសិប្បកម្ម លើការងារស្តង់ដារកម្ពុជា ដោយមានភារកិច្ចដូចតទៅ ÷

- រៀបចំស្តង់ដារជាតិសម្រាប់ផលិតផល ទំនិញ សម្ភារៈ សេវា ការអនុវត្តលើគ្រប់វិស័យ និងការប្រតិបត្តិ និងផ្សព្វផ្សាយ ដើម្បីឱ្យមានការទទួលយកជាទូទៅនៃស្តង់ដារទាំងនោះ
- អនុវត្តការវាយតម្លៃភាពអនុលោមស្របតាមបញ្ញត្តិ ដែលមានចែងក្នុងច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បង្កើតនិងថែទាំមន្ទីរពិសោធន៍ បណ្ណាល័យ មធ្យោបាយ និងឧបករណ៍ផ្សេងទៀត ដើម្បីលើកកម្ពស់ស្តង់ដារូបនីយកម្មនិងគុណភាព

- បញ្ជាក់ភាពអនុលោមតាមស្តង់ដារសម្រាប់ផលិតផល ទំនិញ សារធាតុ សម្ភារៈ និងបរិក្ខារសម្រាប់ការប្រើប្រាស់ក្នុងស្រុក ឬសម្រាប់ការនាំចូលនាំចេញ តាមសំណើរបស់អ្នកស្នើសុំ
- បញ្ជាក់ភាពអនុលោមតាមស្តង់ដារសុវត្ថិភាព សម្រាប់ផលិតផល ទំនិញ សារធាតុ សម្ភារៈ និងបរិក្ខារសម្រាប់ការប្រើប្រាស់ក្នុងស្រុក ឬសម្រាប់ការនាំចេញតាមសំណើរបស់អ្នកស្នើសុំ
- បញ្ជាក់ភាពអនុលោមតាមស្តង់ដារសម្រាប់ប្រព័ន្ធគ្រប់គ្រងផលិតកម្មនិងសេវាកម្ម តាមសំណើរបស់អ្នកស្នើសុំ
- ចុះបញ្ជីផលិតផល បញ្ជាក់ភាពអនុលោមតាមបទបញ្ញត្តិបច្ចេកទេស ឬស្តង់ដារបញ្ជា សម្រាប់ផលិតផល ទំនិញ សារធាតុ សម្ភារៈ និងបរិក្ខារ សម្រាប់ការប្រើប្រាស់ក្នុងស្រុក ឬសម្រាប់ការនាំចូល នាំចេញ តាមសំណើរបស់អ្នកស្នើសុំ
- រៀបចំ និងគ្រប់គ្រងស្តង់ដារ និងបញ្ជាក់មុខសញ្ញា និង/ឬស្តង់ដារប្រើប្រាស់សារធាតុគីមី ក្នុងវិស័យឧស្សាហកម្ម
- ព្យួរទុក ដកហូត និងលុបចោលអាជ្ញាបណ្ណ ប្រើសញ្ញាស្តង់ដារបញ្ជាក់ផលិតផល ឬវិញ្ញាបនបត្របញ្ជាក់ភាពអនុលោមផលិតផល ឬវិញ្ញាបនបត្រ ចុះបញ្ជីផលិតផល ឬវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ
- ស្រាវជ្រាវអំពីស្តង់ដារូបនីយកម្ម
- ផ្តល់សេវាអប់រំ បណ្តុះបណ្តាល និងការពិគ្រោះយោបល់ ដើម្បីផ្សព្វផ្សាយស្តង់ដារូបនីយកម្ម និងគុណភាព
- ទទួលស្គាល់អង្គភាពចេញវិញ្ញាបនបត្រមន្ទីរពិសោធន៍ មធ្យោបាយ និងឧបករណ៍ផ្សេងទៀតរបស់អង្គភាពក្នុងស្រុក និងបរទេសសម្រាប់គោលបំណងរបស់វិទ្យាស្ថាន
- ផ្តល់កិច្ចសហប្រតិបត្តិការជាមួយបុគ្គល អង្គការអន្តរជាតិ ឬសមាគមក្រៅប្រទេស ដែលមានកម្មវត្ថុនិងគោលបំណងដូចគ្នា
- ជំរុញនិងលើកទឹកចិត្តការអនុវត្តស្តង់ដារនិងស្តង់ដារូបនីយកម្ម ឱ្យទៅជាមធ្យោបាយមួយសម្រាប់ការរីកចម្រើននៃសេដ្ឋកិច្ចជាតិ សម្រាប់សុខភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ
- សហការជាមួយអាជ្ញាធរមូលដ្ឋាន ផ្នែកឧស្សាហកម្ម ពាណិជ្ជកម្ម និងអង្គការនានា ដើម្បីធានាការអនុវត្តស្តង់ដារ
- វិភាគ និងធ្វើតេស្តផ្នែករូបសាស្ត្រ គីមីសាស្ត្រ មីក្រូជីវសាស្ត្រ មេកានិក ដើម្បីកំណត់គុណភាព និងលក្ខណៈវិនិច្ឆ័យរបស់ផលិតផល
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**មាត្រា២០.-**

វិទ្យាស្ថានស្តង់ដារកម្ពុជា មាននាយកដ្ឋានក្រោមឱវាទដូចតទៅ ÷

- នាយកដ្ឋានព័ត៌មាន
- នាយកដ្ឋានអភិវឌ្ឍស្តង់ដារ បណ្តុះបណ្តាល និងពិគ្រោះយោបល់
- នាយកដ្ឋានវិញ្ញាបនបត្រកម្ម
- នាយកដ្ឋានបញ្ញត្តកម្ម

- មជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា។

**មាត្រា២១.-**

នាយកដ្ឋានព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានស្តង់ដារកម្ពុជា លើការងារព័ត៌មាន។

នាយកដ្ឋានអភិវឌ្ឍស្តង់ដារ បណ្តុះបណ្តាល និងពិគ្រោះយោបល់ បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានស្តង់ដារកម្ពុជា លើការងារអភិវឌ្ឍស្តង់ដារ បណ្តុះបណ្តាល និងពិគ្រោះយោបល់។

នាយកដ្ឋានវិញ្ញាបនបត្រកម្ម បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានស្តង់ដារកម្ពុជា លើការងារវិញ្ញាបនបត្រកម្ម។

នាយកដ្ឋានបញ្ញត្តកម្ម បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានស្តង់ដារកម្ពុជា លើការងារបញ្ញត្តកម្ម

មជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានស្តង់ដារកម្ពុជា លើការងារពិសោធន៍គុណភាពផលិតផល និងកំណត់លក្ខណៈវិនិច្ឆ័យនៃផលិតផល ក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្ម។

## ជំពូកទី៨
## មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

**មាត្រា២២.-**

មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ បំពេញមុខងារជាសេនាធិការឱ្យក្រសួងឧស្សាហកម្មនិងសិប្បកម្ម លើការងារមាត្រាសាស្ត្រជាតិ ដោយមានភារកិច្ចដូចតទៅ÷

- រៀបចំនិងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសម្រាប់អភិវឌ្ឍន៍ផ្នែកមាត្រាសាស្ត្រ
- អនុវត្តការងារចុះបញ្ជីមាត្រាសាស្ត្រ សិក្សាស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាវិទ្យាសាស្ត្រមាត្រាសាស្ត្រ
- គ្រប់គ្រងនិងថែរក្សាស្តង់ដារគោលជាតិ ស្តង់ដារបន្ទាប់ និងស្តង់ដារប្រតិបត្តិ
- ពិនិត្យវាយតម្លៃលើភាពអនុលោម និងផ្តល់វិញ្ញាបនបត្រទទួលស្គាល់ស្តង់ដារប្រតិបត្តិសម្រាប់ការអនុវត្តដល់អង្គភាពផ្សេងៗ
- ធ្វើតេស្ត វិភាគ និងអនុម័តគំរូជាក់លាក់ណាមួយនៃឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត ពុម្ព និងសំបកវេចខ្ចប់
- ធ្វើព្យាសកម្មស្តង់ដារមាត្រាសាស្ត្រ និងឧបករណ៍មាត្រាសាស្ត្រ
- ធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងបញ្ជាក់ភាពអនុលោមអំពីទម្ងន់ និងរង្វាស់រង្វាល់នៃទំនិញផលិត និងទំនិញវេចខ្ចប់តាមលក្ខខណ្ឌលម្អិតនៃទំនិញវេចខ្ចប់ដែលទាក់ទងនឹងផ្នែកមាត្រាសាស្ត្រ
- ធ្វើការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបញ្ជាក់សមត្ថភាពអប្បបរមានិងអតិបរមាអំពីទម្ងន់ និង/ឬ រង្វាស់រង្វាល់នៃឧបករណ៍មាត្រាសាស្ត្រដែលអនុញ្ញាតឱ្យប្រើប្រាស់ ឬកាន់កាប់បានក្នុងសកម្មភាពពាណិជ្ជកម្ម និងវិស័យផ្សេងៗទៀត ដោយផ្អែកលើប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់

- រៀបចំ សម្របសម្រួល និងគ្រប់គ្រងការបង្កើតនិងការប្រើប្រាស់ប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់ និងប្រព័ន្ធឯកតាផ្សេងៗទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ផ្តល់អាជ្ញាបណ្ណលើការផលិត និងការជួសជុលឧបករណ៍មាត្រាសាស្ត្រ និងអាជ្ញាបណ្ណប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជាស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន
- រៀបចំលិខិតបទដ្ឋានគតិយុត្តនានា និងនីតិវិធីរដ្ឋបាល បច្ចេកទេស ដើម្បីពង្រឹងប្រសិទ្ធភាពការងារមាត្រាសាស្ត្រ
- កសាងសមត្ថភាពធនធានមនុស្ស អភិវឌ្ឍបច្ចេកវិទ្យា ប្រព័ន្ធព័ត៌មានវិទ្យានិងអនុវត្តការវាយតម្លៃសមត្ថភាពបុគ្គល និងអង្គភាពលើវិស័យមាត្រាសាស្ត្រ
- អនុវត្តការងារសហប្រតិបត្តិការជាមួយស្ថាប័នជាតិនិងអន្តរជាតិ ដើម្បីធ្វើសុខដុមនីយកម្មការងារមាត្រាសាស្ត្រ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ លើការត្រួតពិនិត្យបទល្មើសក្នុងការផលិត ជួសជុល ប្រើប្រាស់ និងការធ្វើពាណិជ្ជកម្ម ឧបករណ៍មាត្រាសាស្ត្រ ស្តង់ដារមាត្រាសាស្ត្រ និងប្រើប្រាស់ប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់
- រៀបចំ គ្រប់គ្រងឧបករណ៍មាត្រាសាស្ត្រ ស្តង់ដារមាត្រាសាស្ត្រ ទំនិញផលិត និងទំនិញវេចខ្ចប់ក្នុងស្រុក និងនាំចូល
- គ្រប់គ្រង និងអនុវត្តការងារប្រមូលថ្លៃសេវាកម្ម ការពិន័យ និងកម្រៃផ្សេងៗ ស្របតាមការកំណត់នៃច្បាប់
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**មាត្រា២៣.-**

មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ មាននាយកដ្ឋានក្រោមឱវាទដូចតទៅ ÷

- នាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ
- នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ
- នាយកដ្ឋាន មាត្រាសាស្ត្រឧស្សាហកម្ម
- នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ។

**មាត្រា២៤.-**

នាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ បំពេញមុខងារជាសេនាធិការឱ្យមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិលើការងារវិទ្យាសាស្ត្រមាត្រាសាស្ត្រ។

នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ បំពេញមុខងារជាសេនាធិការឱ្យមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ លើការងារនីត្យានុកូលមាត្រាសាស្ត្រ។

នាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម បំពេញមុខងារជាសេនាធិការឱ្យមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ លើការងារមាត្រាសាស្ត្រឧស្សាហកម្ម។

នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ បំពេញមុខងារជាសេនាធិការឱ្យមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ លើការងារនីតិកម្មមាត្រាសាស្ត្រ។

## ជំពូកទី៩
## អគ្គាធិការដ្ឋាន

**មាត្រា២៥.-**

អគ្គាធិការដ្ឋាន បំពេញមុខងារជាសេនាធិការឱ្យក្រសួងឧស្សាហកម្មនិងសិប្បកម្ម លើការងារអគ្គាធិការកិច្ច ដោយមានភារកិច្ចដូចតទៅ ÷

- ធ្វើអធិការកិច្ចជាប្រចាំទៅលើការគ្រប់គ្រងអង្គភាពក្រោមឱវាទក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី អំពីការប្រព្រឹត្តទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចហើយ និងអំពីមធ្យោបាយកែលម្អការប្រព្រឹត្តទៅរបស់អង្គភាពទាំងនោះ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលរដ្ឋមន្ត្រីប្រគល់ជូន។

## ជំពូកទី១០
## នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**មាត្រា២៦.-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុង បំពេញមុខងារជាសេនាធិការឱ្យក្រសួងឧស្សាហកម្មនិងសិប្បកម្ម លើការងារសវនកម្មផ្ទៃក្នុង ដោយមានភារកិច្ចដូចតទៅ ÷

- អនុវត្តមុខងារសវនកម្មផ្ទៃក្នុង លើការពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់ក្រសួង
- វាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង របស់អង្គភាពក្រោមឱវាទក្រសួង សំដៅពង្រឹងអភិបាលកិច្ចល្អ
- ធ្វើរបាយការណ៍ត្រង់ទៅប្រធានស្ថាប័ន ដោយផ្ញើច្បាប់ចម្លងទៅអាជ្ញាធរសវនកម្មជាតិ និងសម្របសម្រួលការងារជាមួយសមត្ថកិច្ចត្រួតពិនិត្យនានា
- និងអនុវត្តភារកិច្ចផ្សេងទៀតតាមអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ។

## ជំពូកទី១១
## អង្គភាពមូលដ្ឋាន

**មាត្រា២៧.-**

នៅតាមរាជធានី ខេត្តនីមួយៗ មានមន្ទីរឧស្សាហកម្មនិងសិប្បកម្ម និងសាខាសមត្ថកិច្ចជំនាញរាជធានី ខេត្ត ដែលទទួលបន្ទុកអនុវត្ត និងសម្របសម្រួលសកម្មភាពរបស់ក្រសួង។

មន្ទីរឧស្សាហកម្មនិងសិប្បកម្ម បំពេញមុខងារជាតំណាងរបស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម លើការងារសម្រប សម្រួលអង្គភាពថ្នាក់មូលដ្ឋានរបស់ក្រសួង ព្រមទាំងអនុវត្តភារកិច្ចគ្រប់គ្រងវិស័យឧស្សាហកម្មនិងសិប្បកម្ម នៅរដ្ឋបាល ថ្នាក់ក្រោមជាតិ តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម។

## ជំពូកទី១២

## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា២៨.-**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមលក្ខខណ្ឌនៃបទបញ្ញា កំណត់ ក្នុងអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកា ក្នុងបណ្តាក្រសួង។

## ជំពូកទី១៣

## អន្តរប្បញ្ញត្តិ

**មាត្រា២៩.-**

ប្រកាសពាក់ព័ន្ធនឹងការបង្កើត ឬការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពនានា របស់អតីតក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ដែលស្ថិតក្នុងវិស័យឧស្សាហកម្មនិងសិប្បកម្ម ត្រូវមានអានុភាពអនុវត្តបន្ត រហូតដល់មាន ប្រកាសថ្មីរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម។

## ជំពូកទី១៤

## អវសានប្បញ្ញត្តិ

**មាត្រា៣០.-**

អនុក្រឹត្យនេះ ត្រូវជំនួសអនុក្រឹត្យដូចខាងក្រោម÷

- អនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- អនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី២០ ខែ កុម្ភៈ ឆ្នាំ២០០៩ ស្តីពីការដំឡើងមជ្ឈមណ្ឌលមន្ទីរពិសោធន៍ ឧស្សាហកម្មកម្ពុជា ទៅជាថ្នាក់នាយកដ្ឋានចំណុះអគ្គនាយកដ្ឋានឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃវិទ្យាស្ថាន ស្តង់ដារកម្ពុជា
- អនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៣ ស្តីពីការដំឡើងការិយាល័យកម្មសិទ្ធិ ឧស្សាហកម្មនៃនាយកដ្ឋានបច្ចេកទេសឧស្សាហកម្ម ទៅជានាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មនៃអគ្គនាយកដ្ឋាន ឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- អនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការដំឡើងការិយាល័យអាស៊ាន និងការិយាល័យស្តង់ដារឧស្សាហកម្ម ទៅជានាយកដ្ឋានសហប្រតិបត្តិការនិងការងារអាស៊ាន និងជានាយកដ្ឋានស្តង់ដារឧស្សាហកម្មកម្ពុជា នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

**មាត្រា៣១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# អង្គការលេខរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ភ្ជាប់ជាឯកសារឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ៥៧៥.អនក្រ.បក ចុះថ្ងៃទី២៨ខែ ធ្នូ ឆ្នាំ២០១៣



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ០៧៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងរ៉ែនិងថាមពល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤០១ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្ទេរ និងសមាហរណកម្មអាជ្ញាធរប្រេងកាតជាតិកម្ពុជាទៅក្រោមក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងរ៉ែនិងថាមពល។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលបំណងដូចខាងក្រោម ÷

- រៀបចំបេសកកម្ម និងរចនាសម្ព័ន្ធរបស់ក្រសួងរ៉ែនិងថាមពល
- រៀបចំមុខងារនិងភារកិច្ចរបស់អង្គភាពនានានៃក្រសួងរ៉ែនិងថាមពល
- ធានាគុណភាពនិងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារ ក្នុងវិស័យរ៉ែនិងថាមពល រួមទាំងវិស័យប្រេងកាត ឧស្ម័ន និងអគ្គិសនី។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់អង្គភាពនៃក្រសួងរ៉ែនិងថាមពល ទាំងនៅថ្នាក់កណ្តាល និងនៅថ្នាក់មូលដ្ឋាន ដោយគ្របដណ្តប់លើវិស័យរ៉ែនិងថាមពល រួមទាំងវិស័យប្រេងកាត ឧស្ម័ន និងអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## បេសកកម្មនិងរចនាសម្ព័ន្ធ

**មាត្រា៤.-**

ក្រសួងរ៉ែនិងថាមពល បំពេញមុខងារជាសេនាធិការឱ្យរាជរដ្ឋាភិបាល លើបេសកកម្មដឹកនាំនិងគ្រប់គ្រងលើវិស័យរ៉ែនិងថាមពល រួមទាំងវិស័យប្រេងកាត ឧស្ម័ន និងអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា។

បេសកកម្មនេះ ត្រូវធ្វើឡើងតាមរយៈការរៀបចំនិងការអនុវត្តឱ្យបានត្រឹមត្រូវនូវគោលនយោបាយ ក្របខណ្ឌច្បាប់ និងបទបញ្ញាទាំងឡាយ ដែលទាក់ទងនឹងការដឹកនាំនិងការគ្រប់គ្រងវិស័យរ៉ែនិងថាមពល រួមទាំងវិស័យប្រេងកាត ឧស្ម័ន និងអគ្គិសនី។

**មាត្រា៥.-**

ក្រសួងរ៉ែនិងថាមពល មានមុខងារនិងភារកិច្ច ដូចតទៅ÷

- រៀបចំ និងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការ លើវិស័យធនធានរ៉ែ
- គ្រប់គ្រងការធ្វើអាជីវកម្ម អភិវឌ្ឍ និងការប្រើប្រាស់ធនធានរ៉ែ ការប្រើប្រាស់អណ្តូងរ៉ែ ការបន្សុទ្ធ និង ការចម្រាញ់រ៉ែ ព្រមទាំងរាល់សកម្មភាពទាំងឡាយដែលទាក់ទងទៅនឹងប្រតិបត្តិការធនធានរ៉ែ
- គ្រប់គ្រងនិងអនុវត្តការងារសិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយទិន្នន័យភូគព្ភសាស្ត្រ ការសិក្សាស្រាវជ្រាវ រុករកធនធានរ៉ែ និងការការពារសុវត្ថិភាព គុណភាពបរិស្ថាន-សង្គម ក្នុងវិស័យធនធានរ៉ែ
- រៀបចំនិងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និង ផែនការ លើវិស័យប្រេងកាតនិងឧស្ម័ន
- គ្រប់គ្រងលើការស្វែងរុករកនិងអភិវឌ្ឍ ធនធានប្រេងកាត និងឧស្ម័ន លើគ្រប់សកម្មភាពអាជីវកម្មប្រេងកាត និង ឧស្ម័ន អាប់ស្ទ្រីម (Upstream) និងដោនស្ទ្រីម (Downstream) ដែលរួមមានការស្វែងរុករក ការធ្វើអាជីវកម្ម ការសិក្សាវាយតម្លៃ ការអភិវឌ្ឍ ផលិតកម្ម ប្រព្រឹត្តកម្ម ការដឹកជញ្ជូន សន្និធិស្តុកទុក ការចម្រាញ់ ផលិតកម្មគីមីប្រេងកាត ការនាំចេញ-ចូល និងការស្វែងរកទីផ្សារ
- រៀបចំនិងអនុវត្តនយោបាយ យុទ្ធសាស្ត្រ និង ផែនការលើវិស័យថាមពល ក្នុងការសិក្សាស្រាវជ្រាវប្រភពថាមពល ការផលិត ការចែកចាយ ការប្រើប្រាស់ និងការការពារសុវត្ថិភាព
- គ្រប់គ្រងនិងអនុវត្តការសិក្សាស្រាវជ្រាវ ប្រព័ន្ធផ្គត់ផ្គង់និងចែកចាយ ស្ថានីយអគ្គិសនី និងវាយតម្លៃសក្តានុពលវារីអគ្គិសនី ដើម្បីរៀបចំអនុវត្តគម្រោងប្រព័ន្ធអគ្គិសនីណាដែលការផលិតថាមពលអគ្គិសនី ជាគោលបំណងចម្បង

- រៀបចំផែនការ យុទ្ធសាស្ត្រ គោលការណ៍ច្បាប់ និងសហប្រតិបត្តិការជាមួយស្ថាប័ននានា និង ជាមួយបរទេស សំដៅអភិវឌ្ឍលើវិស័យរ៉ែ និង ថាមពល រួមទាំងវិស័យប្រេងកាត ឧស្ម័ន និងអគ្គិសនី។

**មាត្រា៦.-**

ក្រសួងរ៉ែ និងថាមពល មានរចនាសម្ព័ន្ធដូចខាងក្រោម÷

**ក-អង្គភាពថ្នាក់កណ្តាល**

១-ខុទ្ទកាល័យរដ្ឋមន្ត្រី

២-អគ្គនាយកដ្ឋានកិច្ចការទូទៅ

៣-អគ្គនាយកដ្ឋានធនធានរ៉ែ

៤- អគ្គនាយកដ្ឋានប្រេងកាត

៥-អគ្គនាយកដ្ឋានថាមពល

៦-អគ្គាធិការដ្ឋាន

៧-នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**ខ-អង្គភាពថ្នាក់មូលដ្ឋាន**

នៅថ្នាក់មូលដ្ឋាន មានមន្ទីររ៉ែនិងថាមពល និងសាខាសមត្ថកិច្ចជំនាញរាជធានី ខេត្ត។

**មាត្រា៧.-**

អគ្គនាយកដ្ឋាន ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួន ជាជំនួយការ។

អគ្គាធិការដ្ឋាន ដឹកនាំដោយអគ្គាធិការមួយរូប មានឋានៈស្មើអគ្គនាយក និងអមដោយអគ្គាធិការរងមួយចំនួន ឋានៈស្មើអគ្គនាយករង ជាជំនួយការ។

នាយកដ្ឋាន ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ជាជំនួយការ។

អង្គភាពថ្នាក់មូលដ្ឋាននៃក្រសួងរ៉ែនិងថាមពល ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធាន មួយចំនួន ដែលមានឋានៈចាប់ពីអនុប្រធាននាយកដ្ឋានចុះ។

អង្គការលេខរបស់ក្រសួងរ៉ែនិងថាមពល ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៨.-**

ការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពនានា ក្រោមឱវាទរបស់អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាននិង អង្គភាពថ្នាក់មូលដ្ឋាននៃក្រសួងរ៉ែនិងថាមពល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

## ជំពូកទី៣

## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា៩.-**

ខុទ្ទកាល័យរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់តាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន។

## ជំពូកទី៤
## អគ្គនាយកដ្ឋានកិច្ចការទូទៅ

**មាត្រា១០.-**

អគ្គនាយកដ្ឋានកិច្ចការទូទៅ បំពេញមុខងារជាសេនាធិការឱ្យក្រសួងរ៉ែនិងថាមពល ដោយមានភារកិច្ចដូចតទៅ÷

- គ្រប់គ្រងនិងសម្របសម្រួល រាល់សកម្មភាពរដ្ឋបាលរបស់ក្រសួង នៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាល និងអង្គភាពថ្នាក់មូលដ្ឋានក្រោមឱវាទ និងអង្គភាពដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួង
- រៀបចំនិងគ្រប់គ្រងបណ្តាញព័ត៌មានវិទ្យានិងគេហទំព័រ របស់ក្រសួង
- រៀបចំនិងគ្រប់គ្រងរាល់ការងារទាក់ទងថវិកា គណនេយ្យ ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ របស់ក្រសួង
- រៀបចំនិងគ្រប់គ្រងរាល់ការងារទាក់ទងនឹងមន្ត្រីរាជការ
- សហការពិនិត្យនិងផ្តល់យោបល់ និងការពារតាមផ្លូវច្បាប់ ជូនក្រសួង
- សហការសម្របសម្រួលនិងគ្រប់គ្រងការងារទាក់ទងកិច្ចសហប្រតិបត្តិការនិងកិច្ចការអាស៊ានរបស់ក្រសួង។

**មាត្រា១១.-**

អគ្គនាយកដ្ឋានកិច្ចការទូទៅ មាននាយកដ្ឋានក្រោមឱវាទ ចំនួន ៥ ដូចតទៅ÷

-នាយកដ្ឋានរដ្ឋបាលនិងព័ត៌មានវិទ្យា

-នាយកដ្ឋានបុគ្គលិក

-នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ

-នាយកដ្ឋាននីតិកម្ម

-នាយកដ្ឋានសហប្រតិបត្តិការនិងកិច្ចការអាស៊ាន។

អគ្គនាយកដ្ឋានកិច្ចការទូទៅ ទទួលបន្ទុកសម្របសម្រួលមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ដែលតំណាងក្រសួងរ៉ែនិងថាមពល នៅថ្នាក់មូលដ្ឋាន។

**មាត្រា១២.-**

នាយកដ្ឋានរដ្ឋបាលនិងព័ត៌មានវិទ្យា បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅ លើការងាររដ្ឋបាលនិងព័ត៌មានវិទ្យា។

នាយកដ្ឋានបុគ្គលិក បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅ លើការងារបុគ្គលិក។

នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅ លើការងារគណនេយ្យនិងហិរញ្ញវត្ថុ។

នាយកដ្ឋាននីតិកម្ម បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅ លើការងារនីតិកម្ម។

នាយកដ្ឋានសហប្រតិបត្តិការនិងកិច្ចការអាស៊ាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅ លើការងារសហប្រតិបត្តិការនិងអាស៊ាន។

មន្ទីររ៉ែនិងថាមពល បំពេញមុខងារជាតំណាងរបស់ក្រសួងរ៉ែនិងថាមពល លើការងារសម្របសម្រួលអង្គភាពថ្នាក់មូលដ្ឋានរបស់ក្រសួង ព្រមទាំងអនុវត្តភារកិច្ចគ្រប់គ្រងវិស័យរ៉ែនិងថាមពល នៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

## ជំពូកទី៥

## អគ្គនាយកដ្ឋានធនធានរ៉ែ

**មាត្រា១៣.-**

អគ្គនាយកដ្ឋានធនធានរ៉ែ បំពេញមុខងារជាសេនាធិការឱ្យក្រសួងរ៉ែនិងថាមពល លើបេសកកម្មគ្រប់គ្រងធនធានរ៉ែ និងជំរុញការប្រើប្រាស់ព័ត៌មានបច្ចេកវិទ្យាភូគព្ភវិទ្យាសាស្ត្រនិងធនធានរ៉ែ ដើម្បីចូលរួមចំណែកក្នុងកិច្ចអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាជន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមានភារកិច្ចដូចតទៅ÷

- រៀបចំ ចងក្រងគោលនយោបាយ ច្បាប់ បទប្បញ្ញត្តិ និងផែនការយុទ្ធសាស្ត្រនានា ដើម្បីជំរុញអភិវឌ្ឍវិស័យភូគព្ភវិទ្យាសាស្ត្រ និងធនធានរ៉ែនៅកម្ពុជា
- ធ្វើការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យា និងធនធានមនុស្ស ផ្នែកភូគព្ភវិទ្យាសាស្ត្រ ការសិក្សារុករករ៉ែ និងការអភិវឌ្ឍអាជីវកម្មរ៉ែ
- ជំរុញការចូលរួម និងគ្រប់គ្រងការវិនិយោគឯកជនក្នុងវិស័យធនធានរ៉ែ ចាប់ពីការសិក្សារុករករហូតដល់ការធ្វើអាជីវកម្ម និងចម្រាញ់រ៉ែ
- គ្រប់គ្រងការធ្វើអាជីវកម្ម និងការប្រើប្រាស់ធនធានរ៉ែ ខ្សាច់ គ្រួស និងរ៉ែសម្ភារៈសំណង់ផ្សេងៗ ធានាសុចរិតភាព ប្រសិទ្ធភាព និងការពារគុណភាពបរិស្ថាន និងសង្គមក្នុងការវិនិយោគអាជីវកម្ម និងប្រើប្រាស់ធនធានធម្មជាតិទាំងនេះ
- ជំរុញការការពារ អភិរក្ស និងស្តារឡើងវិញនូវបរិស្ថាន និងធនធានធម្មជាតិនៅក្នុងសកម្មភាពអភិវឌ្ឍវិស័យធនធានរ៉ែ
- គ្រប់គ្រងការប្រមូលចំណូលជាតិពាក់ព័ន្ធនឹងវិស័យធនធានរ៉ែ។

**មាត្រា១៤.-**

អគ្គនាយកដ្ឋានធនធានរ៉ែ មាននាយកដ្ឋានក្រោមឱវាទ ចំនួន ៥ ដូចតទៅ÷

-នាយកដ្ឋានភូគព្ភសាស្ត្រ

-នាយកដ្ឋានជំរុញនិងអភិវឌ្ឍធនធានរ៉ែ

-នាយកដ្ឋានគ្រប់គ្រងការស្វែងរុករករ៉ែ

-នាយកដ្ឋានរ៉ែសំណង់

-នាយកដ្ឋានអាជីវកម្មរ៉ែ។

**មាត្រា១៥.-**

នាយកដ្ឋានភូគព្ភសាស្ត្រ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានធនធានរ៉ែ លើការងារភូគព្ភសាស្ត្រ។

នាយកដ្ឋានជំរុញនិងអភិវឌ្ឍធនធានរ៉ែ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានធនធានរ៉ែ លើការងារជំរុញនិងអភិវឌ្ឍធនធានរ៉ែ។

នាយកដ្ឋានគ្រប់គ្រងការស្វែងរុករករ៉ែ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានធនធានរ៉ែ លើការងារគ្រប់គ្រងការស្វែងរុករករ៉ែ។

នាយកដ្ឋានរ៉ែសំណង់ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានធនធានរ៉ែ លើការងាររ៉ែសំណង់។

នាយកដ្ឋានអាជីវកម្មរ៉ែ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានធនធានរ៉ែ លើការងារអាជីវកម្មរ៉ែ។

## ជំពូកទី៦

## អគ្គនាយកដ្ឋានប្រេងកាត

**មាត្រា១៦.-**

អគ្គនាយកដ្ឋានប្រេងកាត បំពេញមុខងារជាសេនាធិការឱ្យក្រសួងរ៉ែនិងថាមពល ដោយមានភារកិច្ចរៀបចំ ចាត់ចែង គ្រប់គ្រង និងផ្តល់ការណែនាំផ្នែកគោលនយោបាយ និងសម្រួលដោះស្រាយការងារស្វែងរុករក និងអភិវឌ្ឍធនធានប្រេងកាត លើគ្រប់សកម្មភាពអាជីវកម្មប្រេងកាត អាប់ស្ទ្រីម(Upstream) និងដោនស្ទ្រីម (Downstream) ដែលរួមមានការស្វែងរុករក ការធ្វើអាជីវកម្ម ការសិក្សាវាយតម្លៃ ការអភិវឌ្ឍ ផលិតកម្ម ប្រព្រឹត្តកម្ម ការដឹកជញ្ជូន សន្និធិស្តុកទុក ការចម្រាញ់ ផលិតកម្មគីមីប្រេងកាត ការនាំចេញ-ចូល និងការស្វែងរកទីផ្សារជាដើម តាមកិច្ចព្រមព្រៀង ឬកិច្ចសន្យាដែល ធ្វើជាមួយនីតិបុគ្គល រូបវន្តបុគ្គល អាជ្ញាធរ ឬក្រុមហ៊ុនប្រេងកាត នានា។

**មាត្រា១៧.-**

អគ្គនាយកដ្ឋានប្រេងកាត មាននាយកដ្ឋានក្រោមឱវាទ ចំនួន ៥ ដូចតទៅ÷

- នាយកដ្ឋានសិក្សាស្រាវជ្រាវប្រេងកាត
- នាយកដ្ឋានបច្ចេកវិទ្យាប្រេងកាត គាំទ្រកិច្ចប្រតិបត្តិការ និងសន្តិសុខថាមពល
- នាយកដ្ឋានគ្រប់គ្រងគម្រោងសម្បទានប្រេងកាត
- នាយកដ្ឋានជំរុញនិងអភិវឌ្ឍធនធានប្រេងកាត
- នាយកដ្ឋានកិច្ចការប្រេងកាតអន្តរជាតិ។

**មាត្រា១៨.-**

នាយកដ្ឋានសិក្សាស្រាវជ្រាវប្រេងកាត បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានប្រេងកាត លើការងារសិក្សាស្រាវជ្រាវប្រេងកាត។

នាយកដ្ឋានបច្ចេកវិទ្យាប្រេងកាត គាំទ្រកិច្ចប្រតិបត្តិការ និងសន្តិសុខថាមពល បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានប្រេងកាត លើការងារបច្ចេកវិទ្យាប្រេងកាត គាំទ្រកិច្ចប្រតិបត្តិការ និងសន្តិសុខថាមពល។

នាយកដ្ឋានគ្រប់គ្រងគម្រោងសម្បទានប្រេងកាត បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានប្រេងកាត លើការងារគ្រប់គ្រងគម្រោងសម្បទានប្រេងកាត។

នាយកដ្ឋានជំរុញនិងអភិវឌ្ឍធនធានប្រេងកាត បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានប្រេងកាត លើការងារជំរុញអភិវឌ្ឍធនធានប្រេងកាត។

នាយកដ្ឋានកិច្ចការប្រេងកាតអន្តរជាតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានប្រេងកាត លើការងារប្រេងកាតអន្តរជាតិ។

## ជំពូកទី៧
## អគ្គនាយកដ្ឋានថាមពល

**មាត្រា១៩.-**

អគ្គនាយកដ្ឋានថាមពល បំពេញមុខងារជាសេនាធិការឱ្យក្រសួងរ៉ែនិងថាមពល លើបេសកកម្មគ្រប់គ្រងធនធានថាមពលអគ្គិសនី និងថាមពលផ្សេងទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមានភារកិច្ចដូចតទៅ÷

- រៀបចំគោលនយោបាយជាតិវិស័យថាមពល
- រៀបចំច្បាប់និងបទប្បញ្ញត្តិវិស័យថាមពល
- រៀបចំយុទ្ធសាស្ត្រ និងផែនការមេអភិវឌ្ឍវិស័យថាមពល
- រៀបចំគោលការណ៍ជំរុញវិនិយោគ និងគោលការណ៍អនុញ្ញាតវិនិយោគវិស័យថាមពល
- សិក្សា ស្រាវជ្រាវ រៀបចំកំណត់សក្តានុពលថាមពល និងអនុវត្តផែនការអភិវឌ្ឍន៍វិស័យថាមពល ដើម្បីធានានិងការពារផលប្រយោជន៍សេដ្ឋកិច្ចជាតិ ដោយកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ដល់សង្គមនិងបរិស្ថាន
- ផ្លាស់ប្តូរបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ ព្រមទាំងពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការនិងពាណិជ្ជកម្មថ្នាក់ជាតិ តំបន់ និងអន្តរជាតិលើវិស័យថាមពល
- រៀបចំស្តង់ដារបច្ចេកទេស និងសុវត្ថិភាពវិស័យថាមពលគ្រប់ប្រភេទ និងបទប្បញ្ញត្តិសម្រាប់អនុវត្ត
- រៀបចំផែនការយុទ្ធសាស្ត្រដើម្បីអភិវឌ្ឍអគ្គិសនីភាវូបនីយកម្មជនបទ
- រៀបចំបណ្តុះបណ្តាលជំនាញបច្ចេកទេស និងគ្រប់គ្រងសេដ្ឋកិច្ចផ្នែកថាមពលគ្រប់ប្រភេទ
- ផ្សព្វផ្សាយអំពីការប្រើប្រាស់ថាមពលគ្រប់ប្រភេទ ដោយសន្សំសំចៃ ប្រសិទ្ធភាព និងអភិរក្ស ធានាបានជាអតិបរមាដល់ការថែរក្សានិងការពារបរិស្ថាន
- ផ្សព្វផ្សាយអំពីការការពារសុវត្ថិភាព សុខុមាលភាពមនុស្ស សត្វ ក្នុងការប្រើប្រាស់ឧបករណ៍សម្ភារៈបរិក្ខាវិទ្យុសកម្ម។

**មាត្រា២០.-**

អគ្គនាយកដ្ឋានថាមពល មាននាយកដ្ឋានក្រោមឱវាទ ចំនួន ៤ ដូចតទៅ÷

-នាយកដ្ឋានអភិវឌ្ឍថាមពល

-នាយកដ្ឋានថាមពលកកើតឡើងវិញនិងថាមពលថ្មី

-នាយកដ្ឋានវារីអគ្គិសនី

-នាយកដ្ឋានបច្ចេកទេសថាមពលនិងកិច្ចការថាមពលបរមាណូ។

**មាត្រា២១.-**

នាយកដ្ឋានអភិវឌ្ឍថាមពល បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថាមពល លើការងារអភិវឌ្ឍថាមពល។

នាយកដ្ឋានថាមពលកកើតឡើងវិញនិងថាមពលថ្មី បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថាមពល លើការងារថាមពលកកើតឡើងវិញនិងថាមពលថ្មី។

នាយកដ្ឋានវារីអគ្គិសនី បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថាមពល លើការងារវារីអគ្គិសនី។

នាយកដ្ឋានបច្ចេកទេសថាមពលនិងកិច្ចការថាមពលបរមាណូ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថាមពល លើការងារបច្ចេកទេសថាមពលនិងកិច្ចការថាមពលបរមាណូ។

## ជំពូកទី៨

## អគ្គាធិការដ្ឋាន

**មាត្រា២២.-**

អគ្គាធិការដ្ឋាន បំពេញមុខងារជាសេនាធិការឱ្យក្រសួងរ៉ែនិងថាមពល លើការងារអគ្គាធិការកិច្ច ដោយមានភារកិច្ចដូចតទៅ÷

- ធ្វើអធិការកិច្ចជាប្រចាំទៅលើការគ្រប់គ្រងអង្គភាពក្រោមឱវាទក្រសួងរ៉ែនិងថាមពល
- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី អំពីការប្រព្រឹត្តទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចហើយ និងអំពីមធ្យោបាយកែលំអការប្រព្រឹត្តទៅរបស់អង្គភាពទាំងនោះ
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនរបស់រដ្ឋមន្ត្រី។

## ជំពូកទី៩

## នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**មាត្រា២៣.-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុង បំពេញមុខងារជាសេនាធិការឱ្យក្រសួងរ៉ែនិងថាមពល លើការងារសវនកម្មផ្ទៃក្នុង ដោយមានភារកិច្ចដូចតទៅ ÷

- អនុវត្តមុខងារសវនកម្មផ្ទៃក្នុង លើការពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់ក្រសួង
- វាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង របស់អង្គភាពក្រោមឱវាទក្រសួង សំដៅពង្រឹងអភិបាលកិច្ចល្អ
- ធ្វើរបាយការណ៍ត្រង់ទៅប្រធានស្ថាប័ន ដោយផ្ញើច្បាប់ចម្លងទៅអាជ្ញាធរសវនកម្មជាតិ និងសម្របសម្រួលការងារជាមួយសមត្ថកិច្ចត្រួតពិនិត្យនានា។

## ជំពូកទី១០

## អង្គភាពមូលដ្ឋាន

**មាត្រា២៤.-**

នៅតាមរាជធានី ខេត្ត នីមួយៗ មានមន្ទីររ៉ែនិងថាមពល និងសាខាសមត្ថកិច្ចជំនាញរាជធានី ខេត្ត ដែលទទួលបន្ទុកអនុវត្តនិងសម្របសម្រួលសកម្មភាពរបស់ក្រសួង។

## ជំពូកទី១១

## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា២៥.-**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមលក្ខខណ្ឌនៃបទបញ្ញាកំណត់ ក្នុងអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកា ក្នុងបណ្តាក្រសួង។

## ជំពូកទី១២

## អន្តរប្បញ្ញត្តិ

**មាត្រា២៦.-**

ប្រកាសពាក់ព័ន្ធនឹងការបង្កើត ឬការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពនានា របស់អតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលស្ថិតក្នុងវិស័យរ៉ែនិងថាមពល ត្រូវមានអានុភាពអនុវត្តបន្ត រហូតដល់មានប្រកាសថ្មីរបស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

## ជំពូកទី១៣

## អវសានប្បញ្ញត្តិ

**មាត្រា២៧.-**

អនុក្រឹត្យនេះ ត្រូវជំនួសអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៩ ស្តីពីការដំឡើងការិយាល័យអាជីវកម្មរ៉ែនិងថ្មសំភារៈសំណង់ នៃនាយកដ្ឋានធនធានរ៉ែ ទៅជានាយកដ្ឋានរ៉ែសំណង់ ចំណុះអគ្គនាយកដ្ឋានធនធានរ៉ែ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

**មាត្រា២៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២៩
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

**អង្គការលេខរបស់ក្រសួងរ៉ែ និង ថាមពល**

ភ្ជាប់ជាឯកសារឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ៧ ខែ ... ឆ្នាំ២០១៣



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១១៧០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

**សម្រេច**

**មាត្រា ១.-**

បំពាក់ **មេដាយមាសការងារ** ចំនួន ០៩គ្រឿង ជូនសិល្បករ-សិល្បការិនី ចំនួន ០៩រូប ដែលបានសហការ និងចូលរួមសម្តែងជូនអង្គភាព ប្រឆាំងអំពើពុករលួយដោយស្ម័គ្រចិត្ត នៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | កញ្ញា | ថាច រ៉ាពេជ្រ | ប្រធានគ្រប់គ្រងក្រុមបង្ហាញម៉ូតខ្មែរម៉ូដែល |
| ២- | កញ្ញា | សា នីទិត | ពិធីករ |
| ៣- | លោក | ម៉េង ប៊ុនឡូ | តារាភាពយន្ត និងតារាចម្រៀង |
| ៤- | លោក | ម៉ូច ម៉ាណែត | តារាចម្រៀង |
| ៥- | កញ្ញា | គីម អានអរុណ | តារាចម្រៀង |
| ៦- | លោក | កែវ ម៉ារ៉ា | តារាចម្រៀង |
| ៧- | អ្នកនាង | សាន សុខគន្ធជា | តារាចម្រៀង |
| ៨- | លោក | សួស សចរាចារ | តារាចម្រៀង |
| ៩- | លោក | វណ្ណា ពិសិដ្ឋ | តារាចម្រៀង |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១១៣១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

### សម្រេច

**មាត្រា១..**

បំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៦រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួនចូលរួមជួយកសាងស្ពាន អាន់ទួរ ធ្វើអំពីថ្ម កំពស់បីជាន់ បណ្តោយប្រវែង ១៦.៤០ម៉ែត្រ ទទឹង ១២.៤០ម៉ែត្រ ស្ថិតនៅភូមិវការលើ ក្រុងកំពង់ចាម ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសស្ថាបនាជាតិ:**

-លោក ស្លេះ អ៊ីសា ថវិកាចំនួន ១០.៧០០ ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិ:**

១-លោក យ៉េប យូសុះ ថវិកាចំនួន ៩.៥០០ ដុល្លារ
២-លោក ឆាំ ម៉ាត់ ថវិកាចំនួន ៩.៧០០ ដុល្លារ
៣-លោក សាន់ មើ ថវិកាចំនួន ៩.៥០០ ដុល្លារ
៤-លោក ស្មាន យូសុះ ថវិកាចំនួន ៨.៧៥០ ដុល្លារ
៥-លោក ស្លេះ មីន ថវិកាចំនួន ៨.៥៥០ ដុល្លារ

**មាត្រា២..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៣
នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១១៧២ អនក្រ.ភគ

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា១.-**

បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនលោក **ស្លេះ ពុនយ៉ាមីន** សប្បុរសជនកម្ពុជា ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាង**ស្ពាន** អាន់នូរ ០១ខ្នង ធ្វើអំពីថ្ម កំពស់បីជាន់ បណ្តោយប្រវែង ១៦.៤០ម៉ែត្រ ទទឹង ១២.៤០ម៉ែត្រ ស្ថិតនៅភូមិរការលើ ក្រុងកំពង់ចាម ខេត្តកំពង់ចាម ។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួលៈ**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១១៧៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ. ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងជំនួយការឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ**ប្រធាននាយកដ្ឋានបន្ថែមលើមុខងារបច្ចុប្បន្ន ដោយមិនយកប្រាក់បៀវត្ស** ដូចមានរាយនាមខាងក្រោម :

១-លោកវរសេនីយ៍ឯក **សៅ ម៉ុនរិទ្ធ** អត្តលេខ ៣៨១០៦
២-លោកវរសេនីយ៍ឯក **កែវ ជា** អត្តលេខ ១២៤៣៩
៣-លោកវរសេនីយ៍ឯក **ស្រេង តេករអាន** អត្តលេខ ០៤៧៨១
៤-លោកវរសេនីយ៍ឯក **ឡុង រុក្ខា** អត្តលេខ ០៧១៣៧

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១១៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខតំណែងនាយនគរបាលថ្នាក់ឧត្តមសេនីយ៍

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១** ៖ ត្រូវបានតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ត្រី **ច័ន្ទ សុវណ្ណា** អត្តលេខ ០៩៣៥ ពីអនុប្រធាននាយកដ្ឋាន ទៅជាប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ( ផ្នែកសន្តិសុខសាធារណៈ ) នៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ។

**មាត្រា ២** ៖ បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៧៥ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា១.-**

ត្រូវបានតែងតាំង លោកស្រី **ម៉ាន់ មុនី** ឋានន្តរសក្តិ អនុមន្ត្រីថ្នាក់លេខ១០ ជាជំនួយការក្រសួងមហាផ្ទៃ មានឋានៈស្មើប្រធាននាយកដ្ឋាន ។

**មាត្រា២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ ៨ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

*កន្លែងទទួល:*
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១១៧៦ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៨៦៦ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៦/០៤៣ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិជំរុញចលនា "ភូមិមួយ ផលិតផលមួយ"
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១១៣/១០៥៩ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការផ្ទេរគណៈកម្មាធិការជាតិជំរុញចលនា "ភូមិមួយ ផលិតផលមួយ" ឱ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- យោងតាមសំណើរបស់ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១** : ត្រូវបានតែងតាំងមន្ត្រី នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយ ផលិតផលមួយ ដូចមានរាយនាមខាងក្រោម÷

១. លោក **ឡៅ សិទ្ធិ** ប្រធាននាយកដ្ឋានទំនាក់ទំនងសាធារណៈ បន្ថែមលើមុខងារបច្ចុប្បន្ន
២. លោក **ទៅ សុខាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍
៣. លោក **ភាំង វ៉ាន់ថា** ប្រធាននាយកដ្ឋានទីផ្សារ និងស្តង់ដារ
៤. លោក **គង់ ចន្នី** ប្រធាននាយកដ្ឋានសាធារណការ
៥. លោកស្រី **ហេង ទេវី** ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

**មាត្រា ២** : បទប្បញ្ញត្តទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង នឹងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ នឹងសាមីជន ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១១ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម

## សម្រេច

**មាត្រា ១.-**

បំពាក់ មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ ជូនជំនាញការជប៉ុន ចំនួន០៥រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជួយជួសជុលប្រព័ន្ធធារាសាស្ត្រ តាមបណ្តាខេត្តមួយចំនួនក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោមជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុន សរុបទឹកប្រាក់ចំនួន ៧.២៤០.៣៦៨,១៧ ដុល្លារអាមេរិក កន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-លោកស្រី គីណាស៊ី យ៉ូកូ តំណាង JICA ប្រចាំព្រះរាជាណាចក្រកម្ពុជា

២-លោក យ៉ូកូអ៊ី ហ៊ីរ៉ូយូគី តំណាង JICA ប្រចាំព្រះរាជាណាចក្រកម្ពុជា

៣-លោក ហូរីអ៊ូជី ម៉ាសាយូគី ប្រធានទីប្រឹក្សាបច្ចេកទេសជប៉ុនប្រចាំគំរោង TSC3

៤-លោក អាតាហ្គោ តូគួយូគី ជំនាញការបច្ចេកទេសជប៉ុនប្រចាំគំរោង TSC3

៥-លោក អ៊ីម៉ាមូរ៉ា ម៉ាសារុ ជំនាញការបច្ចេកទេសជប៉ុនប្រចាំគំរោង TSC3

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១១៣៨ - អនក្រ - បក

# អនុក្រឹត្យ
# ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យ លេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា ១:** តែងតាំងមន្ត្រីរាជការចំនួន ០២ រូប ជាទីប្រឹក្សាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖

១. លោក ជាង ស៊ាងវេង មានឋានៈស្មើ អគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ន

២. លោក ឆាយ សុភា មានឋានៈស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីជនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៧៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញអនុក្រឹត្យ លេខ ៣០ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- យោងតាមសំណើរបស់ឯកឧត្តម **ញឹម វណ្ណដា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានទី ១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

### សម្រេច

**មាត្រា ១:** តែងតាំងជំនួយការ ឯកឧត្តម ញឹម វណ្ណដា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស មានដូចខាងក្រោម៖

១- លោក ប្រាក់ គីមហុង មានឋានៈស្មើ អគ្គនាយករង
២- លោក ញឹម សុផល មានឋានៈស្មើ ប្រធាននាយកដ្ឋាន
៣- លោក ផៃ សុភាព មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ២:** តែងតាំងជំនួយការ ឯកឧត្តម លី ធុជ ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស មានដូចខាងក្រោម៖

១- លោក ធិន ភិរុណ មានឋានៈស្មើ អគ្គនាយករង
២- លោក លី ច័ន្ទដារា មានឋានៈស្មើ ប្រធាននាយកដ្ឋាន
៣- លោកស្រី ប៉ាន លក្ខិណា មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ៣:** តែងតាំងមន្ត្រីរាជការចំនួន ០៤ រូប នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានដូចខាងក្រោម៖

១- លោក ចយ ភាព ជាប្រធាននាយកដ្ឋានសម្របសម្រួលការងារុករក ឧបទ្ទវហេតុយន្តហោះ និងនាវា

២- លោក ម៉ី វិរត្ន ជាប្រធានមជ្ឈមណ្ឌលសម្របសម្រួលកិច្ចការគ្រោះអាសន្ន និងអាស៊ាន មានឋានៈស្មើ ប្រធាននាយកដ្ឋាន

៣- លោក នាង ផែន ជាប្រធាននាយកដ្ឋានឆ្លើយតប សង្គ្រោះបន្ទាន់ និងស្តារឡើងវិញ

៤- លោក សៀក វិចិត្រ ជាប្រធាននាយកដ្ឋានព័ត៌មាន និងទំនាក់ទំនង ។

**មាត្រា ៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីជន ដូចមានចែងក្នុងមាត្រា ១ មាត្រា ២ និងមាត្រា ៣ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី* ២០ *ខែ* ធ្នូ *ឆ្នាំ ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៤០ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យ លេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

### សម្រេច

**មាត្រា ១ៈ** តែងតាំងលោកស្រី **ឈិន រ៉ែម** ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន ក្រសួងផែនការ ។

**មាត្រា ២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ និងសាមីជន ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៨១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងសមាសភាព

## ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិអតីតយុទ្ធជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១០/៥៩៥ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ ស្តីពីរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការបង្កើតបេឡាជាតិអតីតយុទ្ធជន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

# សម្រេច

## មាត្រា ១.-

ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃបេឡាជាតិអតីតយុទ្ធជនដូចមានរាយនាមខាងក្រោមៈ

| | | |
|---|---|---|
| ១-ឯកឧត្តម **គឹម ហុង** | តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ប្រធាន |
| ២-ឯកឧត្តម **ឯក ធីរដេដ្ឋ** | តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៣-លោក **ថោង ជ័យវាសនា** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤-ឧត្តមសេនីយ៍ត្រី **ហុក ថាវណ្ណា** | តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៥-ឧត្តមសេនីយ៍ឯក **ទូច សុវណ្ណារិទ្ធ** | តំណាងក្រសួងការពារជាតិ | សមាជិក |
| ៦-លោកវេជ្ជបណ្ឌិត **ម៉ី សំបូរ** | តំណាងក្រសួងសុខាភិបាល | សមាជិក |
| ៧-ឯកឧត្តម **ខៀវ ច័ន្ទម៉ុនធឿន** | តំណាងក្រសួងមុខងារសាធារណៈ | សមាជិក |
| ៨-លោក **ហែម ម៉ូរ៉ា** | នាយកបេឡាជាតិអតីតយុទ្ធជន | សមាជិក |
| ៩-លោក **ហេង វឌ្ឍធីរិទ្ធ** | តំណាងបុគ្គលិកនៃបេឡាជាតិអតីតយុទ្ធជន | សមាជិក |

## មាត្រា ២.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

## មាត្រា ៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ៨ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួលៈ
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៣
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥១ សសរ.

## សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១០៥ / ០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ១៥៨ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់
- យោងតាមស្មារតីអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់

### សម្រេច

**ប្រការ១ :** ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ មានដូចខាងក្រោម ÷

១- សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាប្រធានកិត្តិយស

២- ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រធាន

៣- ឯកឧត្តម **មុត ខៀវ** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អនុប្រធានអចិន្ត្រៃយ៍

៤- លោកជំទាវ **ស៊ី ដេម៉ឺន** រដ្ឋលេខាធិការក្រសួងកិច្ចការនារី អនុប្រធាន

៥- ឯកឧត្តម **នុត សារអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន

៦- ឯកឧត្តម **កែវ រ៉េមី** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

| | | | |
|---|---|---|---|
| ៧ - ឯកឧត្តម | **ជុំ គីមឡេង** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨ - ឯកឧត្តម | **ហ៊ុយ ហានសុង** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៩ - ឯកឧត្តម | **ហេង តៃគ្រី** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១០ - ឯកឧត្តម | **ឆ្លោក ជន** | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | សមាជិក |
| ១១ - ឯកឧត្តម | **ធ្វី មេង** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១២ - ឯកឧត្តម | **ពិត ចំណាន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៣ - ឯកឧត្តម | **សន ស៊ីថន** | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១៤ - ឯកឧត្តម | **ម៉ៅ អាយុទ្ធ** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១៥ - ឯកឧត្តម | **រស់ សូផាន់** | រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៦ - លោកជំទាវ | **ម៉ែន នារីសោភ័គ** | អគ្គលេខាធិការរងកាកបាទក្រហមកម្ពុជា | សមាជិក |
| ១៧ - ឯកឧត្តម | **ឆេស ហេង** | អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ | សមាជិក |
| ១៨ - ឯកឧត្តម | **សរ សុពុត្រា** | អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រធានលេខាធិការដ្ឋាន នៃ គ.ម.ច. | ជាលេខាធិការ |

**ប្រការ២**: សេចក្តីសម្រេចទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៣**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត និងសមាសភាពដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការសិក្សាស្រាវជ្រាវការកែទម្រង់ការបោះឆ្នោត

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការសិក្សាស្រាវជ្រាវការកែទម្រង់ការបោះឆ្នោត ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម ស ខេង | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២-ឯកឧត្តម ជិន ម៉ិនស៊ាន | ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស | អនុប្រធាន |
| ៣-ឯកឧត្តម ព្រុំ សុខា | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៤-ឯកឧត្តម សក់ សេដ្ឋា | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៥-ឯកឧត្តម ប៉ាន សូរស័ក្តិ | រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦-ឯកឧត្តម កើត រិទ្ធ | រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | សមាជិក |
| ៧-ឯកឧត្តម លេង ទី | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៨-ឯកឧត្តម ឌុច សុន | អគ្គនាយករដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ | សមាជិក |
| ៩-ឯកឧត្តម ឧត្តមសេនីយ៍ឯក ម៉ូលី ជា ប្រធានក្រុមប្រឹក្សានីតិកម្ម ក្រសួងមហាផ្ទៃ | | សមាជិក |
| ១០-លោក ប្រាក់ សំអឿន | ប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ ក្រសួងមហាផ្ទៃ | សមាជិក |

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ច :

-សិក្សាស្រាវជ្រាវ អំពីច្បាប់ លិខិតបទដ្ឋាននានា និងដកស្រង់បទពិសោធន៍ ពាក់ព័ន្ធនឹងការបោះឆ្នោត ពីបណ្តាប្រទេសនានា ។

-រៀបចំសិក្ខាសាលាជាតិ ដើម្បីប្រមែប្រមូលមតិយោបល់ និងអនុសាសន៍នានា ពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ រួមមាន: តំណាងស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិ តំណាងគណបក្សនយោបាយដែលចុះបញ្ជី តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តំណាងស្ថានទូតបណ្តាប្រទេសជាមិត្ត តំណាងសង្គមស៊ីវិល អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍នានា ស្ថាប័ន និងអ្នកពាក់ព័ន្ធដទៃទៀត សំដៅកសាងអោយបាននូវក្របខ័ណ្ឌកំណែទម្រង់ការបោះឆ្នោត ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស និងនីតិរដ្ឋ ។

-ធ្វើរបាយការណ៍ជូននាយករដ្ឋមន្ត្រី អំពីលទ្ធផលនៃសិក្ខាសាលា ជាអាទិ៍ មតិយោបល់ និងអនុសាសន៍នានា ដើម្បីកសាងក្របខ័ណ្ឌកំណែទម្រង់ការបោះឆ្នោត ដើម្បីស្នើសុំគោលការណ៍ពីនាយករដ្ឋមន្ត្រី ដាក់ប្រជុំឆ្លងគណៈរដ្ឋមន្ត្រី ពិនិត្យ និងសំរេច ។

**ប្រការ ៣ :** គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រសួងមហាផ្ទៃ ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋាន គ.ជ.ប
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចប្រការ ៤
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៥៤. សសរ**

# សេចក្តីសម្រេច

**ស្តីពី**

**ការបង្កើតគណៈកម្មការតាមដាន ត្រួតពិនិត្យ សភាពការណ៍សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើត គណៈកម្មការតាមដាន ត្រួតពិនិត្យសភាពការណ៍សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ស ខេង** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២. ឯកឧត្តម **ទៀ បាញ់** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |
| ៣. ឯកឧត្តម **អ៊ឹម ឈុនលឹម** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៤. ឯកឧត្តម **ចម ប្រសិទ្ធ** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ៥. ឯកឧត្តម **ស៊ុន ចាន់ថុល** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦. ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧. ឯកឧត្តម **ខៀវ កាញារីទ្ធ** | រដ្ឋមន្ត្រីក្រសួងព័ត៌មាន | សមាជិក |
| ៨. ឯកឧត្តម **អង្គ វង្សវឌ្ឍានា** | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សមាជិក |
| ៩. ឯកឧត្តម **អ៊ិត សំហេង** | រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១០. ឯកឧត្តម **វង សូត** | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |

១១. ឯកឧត្តម **មិន ឃិន** រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា សមាជិក
១២. ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
១៣. ឯកឧត្តម **ប្រាក់ សុខុន** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក
១៤. ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន សមាជិក
១៥. ឯកឧត្តម **សុខ ចិន្តាសោភា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
១៦. ឯកឧត្តម **ឯម សំអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក
១៧. ឯកឧត្តម **ព្រុំ សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក
១៨. ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក
១៩. ឯកឧត្តម **អ៊ុច បូរិទ្ធ** រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក
២០. ឯកឧត្តម **ស្វាយ ស៊ីថា** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
២១. ឯកឧត្តម **ចាយ សាំងយុន** រដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក
២២. ឯកឧត្តមនាយឧត្តមសេនីយ៍ **ប៉ុល សារឿន** អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ សមាជិក
២៣. ឯកឧត្តមនាយឧត្តមសេនីយ៍ **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ សមាជិក
២៤. ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
២៥. ឯកឧត្តម **ប៉ា សុជាតិវង្ស** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ សមាជិក

**ប្រការ ២ .-**

គណៈកម្មការនេះ មានតួនាទី ភារកិច្ច ដូចខាងក្រោម៖

- តាមដាន ត្រួតពិនិត្យសភាពការណ៍សន្តិសុខ សណ្តាប់ធ្នាប់សង្គម
- ចាត់វិធានការការពារ បង្ការ និងទប់ស្កាត់បទល្មើសគ្រប់ប្រភេទ
- ប្រមែប្រមូលព័ត៌មាន ព្រមទាំងធ្វើការសិក្សាស្រាវជ្រាវ ស៊ើបអង្កេតរាល់សកម្មភាពនានា ដែលបង្កឲ្យមានចលាចល អំពើហឹង្សា និងអសន្តិសុខក្នុងសង្គម
- ធ្វើទំនាក់ទំនងផ្នែកការទូត ក្នុងករណីចាំបាច់ ពាក់ព័ន្ធទៅនឹងសភាពការណ៍នយោបាយ និងសន្តិសុខនៅកម្ពុជា
- ប្រធានគណៈកម្មការមានភារកិច្ចរាយការណ៍អំពីសភាពការណ៍សន្តិសុខ និងសណ្តាប់ធ្នាប់សង្គមជាប្រចាំជូន **សម្តេចនាយករដ្ឋមន្ត្រី**
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពីនាយករដ្ឋមន្ត្រី។

**ប្រការ ៣ .-**

ត្រូវបានបង្កើតអនុគណៈកម្មការជំនាញចំនួន ០៥ ដើម្បីជាសេនាធិការដល់**គណៈកម្មការតាមដាន ត្រួតពិនិត្យសភាពការណ៍សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម** ដែលមានសមាសភាព និងតួនាទី ភារកិច្ចដូចខាងក្រោម៖

**ក. អនុគណៈកម្មការសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ**

១. ឯកឧត្តម **ឯម សំអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ប្រធាន
២. ឯកឧត្តម **អ៊ុក គឹមលេខ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន
៣. ឯកឧត្តមនាយឧត្តមសេនីយ៍ **ប៉ុល សារឿន** អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អនុប្រធាន
៤. ឯកឧត្តមនាយឧត្តមសេនីយ៍ **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ អនុប្រធាន
៥. ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

៦. ឯកឧត្តមឧត្តមសេនីយ៍ឯក **ម៉ៅ ប៊ុនណារិន** អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ សមាជិក
៧. ឯកឧត្តមឧត្តមសេនីយ៍ឯក **សុខ ផល** អគ្គស្នងការរងនគរបាលជាតិ សមាជិក
៨. ឯកឧត្តមឧត្តមសេនីយ៍ឯក **ជួន សុវណ្ណ** អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ សមាជិក
៩. ឯកឧត្តមឧត្តមសេនីយ៍ឯក **ជា សុគន្ធា** អគ្គលេខាធិការរង ក្រសួងមហាផ្ទៃ សមាជិក
១០. ឯកឧត្តមឧត្តមសេនីយ៍ឯក **ឆៃ ស៊ីណារិទ្ធ** ប្រធាននាយកដ្ឋានសន្តិសុខផ្ទៃក្នុង អគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក
១១. ឯកឧត្តមឧត្តមសេនីយ៍ឯក **ឃុន សំបូរ** ប្រធាននាយកដ្ឋានចារកម្ម អគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក
១២. តំណាងអង្គភាពចារកិច្ចនៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ សមាជិក
១៣. នាយការិយាល័យទី២ បញ្ជាការដ្ឋានកងទ័ពជើងគោក សមាជិក

អនុគណៈកម្មការនេះ មានភារកិច្ចតាមដាន និងវាយតម្លៃសភាពការណ៍ប្រចាំថ្ងៃ ការងារពាក់ព័ន្ធទៅនឹងសន្តិសុខ សុវត្ថិភាពនិង សណ្តាប់ធ្នាប់សង្គម និងចាត់វិធានការស្របតាមគោលការណ៍ច្បាប់ ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសនានា។ ព្រមជាមួយនេះ ត្រូវយកចិត្តទុកដាក់តាមដាន វិភាគ វាយតម្លៃរាល់បាតុភាព ទំនាស់ផ្សេងៗរវាងប្រជាពលរដ្ឋ និងប្រជាពលរដ្ឋ ការទាមទាររបស់ប្រជាពលរដ្ឋ ក៏ដូចជាក្នុងការប្រមូលផ្តុំទាមទារតវ៉ា ឬការធ្វើបាតុកម្ម កូដកម្មនានា។

## ខ. អនុគណៈកម្មការច្បាប់

១. ឯកឧត្តម **អង្គ វង្សវឌ្ឍានា** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធាន
២. ឯកឧត្តម **ព្រុំ សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន
៣. ឯកឧត្តម **ប៉ុល លឹម** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន
៤. ឯកឧត្តម **កើត រិទ្ធ** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ អនុប្រធាន
៥. ឯកឧត្តម **ផ្លោក ផន** រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា សមាជិក
៦. ឯកឧត្តម **អ៊ុំ មាន** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
៧. ឯកឧត្តមរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក
៨. ឯកឧត្តម **ឌុន ប៊ុនថាល់** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក
៩. ឯកឧត្តមឧត្តមសេនីយ៍ឯក **កង សុខន** អគ្គស្នងការរងនគរបាលជាតិ សមាជិក

អនុគណៈកម្មការនេះ មានភារកិច្ចក្តាប់សភាពការណ៍ប្រចាំថ្ងៃពាក់ព័ន្ធទៅនឹងសកម្មភាពនៃការជួបជុំប្រមូលផ្តុំជាសាធារណៈ ក្នុងគោលបំណងសំដែងមតិ ឬការទាមទារតវ៉ានានា ដើម្បីពិនិត្យអំពីភាពស្របច្បាប់នៃសកម្មភាពទាំងនោះ និងផ្តួចផ្តើមអំពីវិធានការសមស្របសំដៅពង្រឹងលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។

## គ. អនុគណៈកម្មការការងារសារព័ត៌មាន និងសាធារណៈមតិ

១. ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន ប្រធាន
២. ឯកឧត្តម **ស្វាយ ស៊ីថា** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន
៣. ឯកឧត្តម **ទិត សុធា** អនុប្រធានអង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស សមាជិក
៤. ឯកឧត្តម **កុយ គួង** អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក
៥. ឯកឧត្តម **ម៉ែន សាម៉ន** អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន សមាជិក

៦. ឯកឧត្តមឧត្តមសេនីយ៍ឯក **ខៀវ សុភ័គ** អគ្គលេខាធិការ ក្រសួងមហាផ្ទៃ សមាជិក
៧. ឯកឧត្តម **ជុន វ៉ាត** អគ្គលេខាធិការអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍ វិស័យទូរគមនាគមន៍ព័ត៌មានវិទ្យា (NIDA) សមាជិក
៨. ឯកឧត្តមឧត្តមសេនីយ៍ឯក **គៀត ច័ន្ទថារិទ្ធ** ប្រធានសេនាធិការដ្ឋាន អគ្គស្នងការនគរបាលជាតិ សមាជិក
៩. ឧត្តមសេនីយ៍ត្រី **ជា អេងយ៉ុង** ស្នងការរងនៃស្នងការដ្ឋានព័ត៌មាននិងសន្តិសុខ នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

អនុគណៈកម្មការនេះ មានភារកិច្ចតាមដាន និងប្រមែប្រមូលសភាពការណ៍ ព័ត៌មាន ពីគ្រប់ប្រភព ដើម្បីពិចារណា វិភាគ វាយតម្លៃ សន្និដ្ឋាន ក៏ដូចជាជូនព័ត៌មានដល់សាធារណជនទូទៅ អំពីរាល់ហេតុការណ៍ដែលកើតឡើងពិសេសពាក់ព័ន្ធដល់សន្តិសុខ សណ្តាប់ធ្នាប់ និង សុវត្ថិភាពសង្គម។ ទន្ទឹមនេះ ត្រូវយកចិត្តទុកដាក់ចំពោះព័ត៌មានដែលប្រាសចាកការពិត ពុំមានប្រភពច្បាស់លាស់ ព័ត៌មានមានលក្ខណៈញុះញង់ អុជអាល បង្កឲ្យមានអំពើហិង្សា និងអំពើចលាចលក្នុងសង្គម។

### ឃ. អនុគណៈកម្មការផ្ទៃក្នុង

១. ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ប្រធាន
២. ឯកឧត្តមរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុប្រធាន
៣. ឯកឧត្តមរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា អនុប្រធាន
៤. ឯកឧត្តមរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម អនុប្រធាន
៥. ឯកឧត្តមរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
៦. ឯកឧត្តម **លេង វី** អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ សមាជិក
៧. ឯកឧត្តម **ឌុច សុន** អគ្គនាយករដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ សមាជិក
៨. ឯកឧត្តម **ប៉ា សុជាតិវង្ស** អភិបាលរាជធានីភ្នំពេញ សមាជិក
៩. ឯកឧត្តមឧត្តមសេនីយ៍ឯក **ម៉ៅ ច័ន្ទតារា** អគ្គស្នងការរងនគរបាលជាតិ សមាជិក
១០. ឯកឧត្តមឧត្តមសេនីយ៍ឯក **យុន ឈុន្នី** អគ្គស្នងការរងនគរបាលជាតិ សមាជិក
១១. ឯកឧត្តមឧត្តមសេនីយ៍ឯក **សួស អង្គារ៍** អគ្គស្នងការរងនគរបាលជាតិ សមាជិក
១២. ឯកឧត្តម **រស់ វុណា** អគ្គលេខាធិការរង ក្រសួងមហាផ្ទៃ សមាជិក

អនុគណៈកម្មការនេះ មានភារកិច្ចអប់រំសាធារណៈជនទូទៅ អំពីការប្រើប្រាស់សិទ្ធិរបស់ខ្លួន ឲ្យបានត្រឹមត្រូវតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។

### ង. អនុគណៈកម្មការការងារការទូត

១. ឯកឧត្តម **អ៊ុច បូរិទ្ធ** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ប្រធាន
២. ឯកឧត្តម **ងី ច័ន្ទ្រផល** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន
៣. ឯកឧត្តមឧត្តមសេនីយ៍ឯក **ថោង លីម** ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ អគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក
៤. ឯកឧត្តមឧត្តមសេនីយ៍ទោ **ប៉ោ ភក្តិ** អគ្គលេខាធិការរង ក្រសួងមហាផ្ទៃ សមាជិក

អនុគណៈកម្មការនេះ មានភារកិច្ចធ្វើការទំនាក់ទំនងជាមួយស្ថានទូត និងអង្គការអន្តរជាតិនានា ដើម្បីធ្វើការស្រាយបំភ្លឺ ជូនព័ត៌មាន ឬពិគ្រោះយោបល់ ក្នុងករណីចាំបាច់ ពាក់ព័ន្ធទៅនឹងសភាពការណ៍នយោបាយ សន្តិសុខ សុវត្ថិភាពសង្គមនៅកម្ពុជា។

**ប្រការ ៤ .-**

គណៈកម្មការ និងអនុគណៈកម្មការអាចកោះអញ្ជើញរដ្ឋមន្ត្រី ឬតំណាងក្រសួង ស្ថាប័ន និងអាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធចូលរួមប្រជុំតាមការចាំបាច់។

ប្រធាន អនុប្រធាន និងសមាជិកអនុគណៈកម្មការនីមួយៗ មានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទក្នុងក្រសួង ស្ថាប័នសាមី តាមការចាំបាច់។

ក្នុងការអនុវត្តការងារ អនុគណៈកម្មការដូចមានចែងក្នុងប្រការ ៣ នៃសេចក្តីសម្រេចនេះ ត្រូវធ្វើការប្រជុំពិភាក្សា ផ្តួចផ្តើមអំពីវិធានការណ៍នានា ដើម្បីសុំការសម្រេចពី**គណៈកម្មការតាមដាន ត្រួតពិនិត្យសភាពការណ៍សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម**។ ក្នុងករណីចាំបាច់ ប្រធានអនុគណៈកម្មការអាចរាយការណ៍ និងសុំយោបល់ដឹកនាំជាបន្ទាន់ពីប្រធាន**គណៈកម្មការតាមដាន ត្រួតពិនិត្យសភាពការណ៍សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម**។

**ប្រការ ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:

*-ក្រសួងព្រះបរមរាជវាំង*
*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ដូចប្រការ៥*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១១២៥ សហវ.....

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣

**ប្រកាស**

**ស្តីពីការបន្ថែមឥណទានថវិកា**

**ជូនមន្ទីរព័ត៌មាន ខេត្តបន្ទាយមានជ័យ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣, ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០, ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក, ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី ១៨ ខែ វិច្ឆកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ២០ អនក្រ.បក, ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក, ចុះថ្ងៃទី១៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៦ អនក្រ.បក, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញប្រកាសលេខ ១០១៨ សហវ.ប្រក, ចុះថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូក តាមគណនីនិងអនុគណនី សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- យោងលិខិតលេខ ១២៤/១៣ ពមខបជ, ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣ របស់មន្ទីរព័ត៌មាន ខេត្តបន្ទាយមានជ័យ និងចំណារបញ្ជូនលេខ ១៥៣៦ ព.ម, ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៣ របស់ក្រសួងព័ត៌មាន

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១** : ដោយអនុលោមទៅតាមមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ត្រូវបានអនុញ្ញាតឱ្យបំពេញបន្ថែមឥណទានថវិកាជំពូក ៦៤ (បន្ទុកបុគ្គលិក) ចំនួនៈ ៩.៤៣០.០០០រៀល (ប្រាំបួនលានបួនរយសាមសិបពាន់រៀលគត់) ជូនមន្ទីរព័ត៌មាន ខេត្តបន្ទាយមានជ័យនៃក្រសួងព័ត៌មាន សម្រាប់ការគ្រប់គ្រងថវិកាឆ្នាំ២០១៣ ដូចមានបញ្ជាក់ខាងក្រោមៈ

*(ឯកតា:ពាន់រៀល)*

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ ឆ្នាំ២០១៣ | ឥណទាន បច្ចុប្បន្ន | ឥណទាន បំពេញបន្ថែម | ឥណទានថ្មី ក្រោយបន្ថែម |
|---|---|---|---|---|---|---|---|
| | | | **សរុប** | | | **9.430** | |
| 64 | 644 | 6441 | បៀវត្សមូលដ្ឋានបុគ្គលិកជាប់កិច្ចសន្យា | 16.800 | 20.810 | 9.430 | 30.240 |

**ប្រការ២** : ឥណទានថវិកាដែលបានបន្ថែមក្នុងប្រការ១ខាងលើនេះ ត្រូវបានអនុញ្ញាតឱ្យបំពេញបន្ថែមទៅក្នុងសៀវភៅថវិកា របស់មន្ទីរព័ត៌មាន ខេត្តបន្ទាយមានជ័យ ដើម្បីបំពេញបន្ថែមលើ (បន្ទុកបុគ្គលិក) បៀវត្សមូលដ្ឋានបុគ្គលិកជាប់កិច្ចសន្យា ដែលខ្វះក្នុងឆ្នាំ២០១៣។

**ប្រការ៣** : ឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន ឯកឧត្តមអភិបាលខេត្តបន្ទាយមានជ័យ ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**បណ្ឌិត. អូន_ព័ន្ធមុនីរ័ត្ន**

<u>ចម្លងជូន</u>

-អគ្គនាយកដ្ឋានរតនាគារជាតិ

-មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបន្ទាយមានជ័យ

- រតនាគារខេត្តបន្ទាយមានជ័យ

“ដើម្បីអនុវត្ត ”

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...១៦៧៩...សហវ.....

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣

# ប្រកាស
## ស្តីពីការបន្ថែមឥណទានថវិកា ជូនមន្ទីរសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ខេត្តព្រះសីហនុ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣,ចុះថ្ងៃ ទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំង រាជ រដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤,ចុះថ្ងៃ ទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តី ពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះ ថ្ងៃ ទី ២៤ ខែ មករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦,ចុះ ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះ ថ្ងៃ ទី ២៦ ខែ ធ្នូ ឆ្នាំ ២០១២ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក,ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ២០ អនក្រ.បក, ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក, ចុះថ្ងៃទី១៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៦ អនក្រ.បក, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១៣
- បានឃើញប្រកាសលេខ ១០១៨ សហវ.ប្រក, ចុះថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ ផ្ទៃក្នុងជំពូក តាមគណនី និង អនុគណនី សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១៣
- យោងលិខិតលេខ ១៦៥/១៣ សអយ- ខសន របស់មន្ទីរសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទាខេត្តព្រះសីហនុ និង លិខិតលេខ ១៩៤៧ ស.អ.យ ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៣ របស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរសព្ទ័ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA. Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១:** ដោយអនុលោមទៅតាមមាត្រា២៦នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី១៣ខែឧសភា ឆ្នាំ២០០៨ ត្រូវបានអនុញ្ញាតឱ្យបំពេញបន្ថែមឥណទានថវិកាជំពូក ៦៤(បន្ទុកបុគ្គលិក)ចំនួនៈ៣៩០.០៩៥.០០០រៀល(បីរយកៅសិបលានកៅសិបប្រាំពាន់រៀលគត់)ជូនមន្ទីរសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទាខេត្តព្រះសីហនុនៃក្រសួងសង្គមអតីតយុទ្ធជននិងយុវនីតិសម្បទាសម្រាប់ការគ្រប់គ្រងថវិកា ឆ្នាំ ២០១៣ ដូចមានបញ្ជាក់ខាងក្រោមៈ

(ឯកតាៈពាន់រៀល)

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ ឆ្នាំ ២០១៣ | ឥណទាន បច្ចុប្បន្ន | ឥណទាន បំពេញបន្ថែម | ឥណទានថ្មី ក្រោយបន្ថែម |
|---|---|---|---|---|---|---|---|
| | | | បន្ថែមជំពូក៦៤ | | | 390.095 | |
| 64 | 645 | 6454 | ឧបត្ថម្ភនិវត្តជន | 3.409.000 | 3.409.000 | 390.095 | 3.799.095 |

**ប្រការ២** ឥណទានថវិកាដែលបានបន្ថែមក្នុងប្រការ១ ខាងលើនេះ ត្រូវបានអនុញ្ញាតឱ្យបំពេញបន្ថែមទៅក្នុងសៀវភៅថវិការបស់មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និង យុវនីតិសម្បទាខេត្តព្រះសីហនុ សម្រាប់ការគ្រប់គ្រងថវិកា ឆ្នាំ ២០១៣ ដើម្បីបំពេញបន្ថែមលើប្រាក់ឧបត្ថម្ភនិវត្តជនដែលខ្វះក្នុងឆ្នាំ ២០១៣ ។

**ប្រការ៣:** ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ឯកឧត្តមអភិបាលខេត្តព្រះសីហនុជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត អូន-ព័ន្ធមុនីរ័ត្ន**

<u>ចម្លងជូន</u>

- អគ្គនាយកដ្ឋានរតនាគារជាតិ
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តព្រះសីហនុ
- រតនាគារខេត្តព្រះសីហនុ

  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១១៧០ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ ២០១៣

# ប្រកាស
## ស្ដីពីការធ្វើនិយ័តកម្មឥណទានថវិកា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣, ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ , ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក , ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ និងអនុក្រឹត្យពាក់ព័ន្ធ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤អនក្រ.បក , ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៦អនក្រ.បក , ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្ដីពីការបែងចែកចំណាយថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្ដីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៣
- បានឃើញប្រកាសលេខ ១០១៨សហវ.ប្រក , ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១២ ស្ដីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនី សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- យោងលិខិតលេខ២១៦៨លស, ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១:** ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិការបស់ក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ នូវការធ្វើនិយ័តកម្មឥណទានថវិកា ដូចមានបញ្ជាក់ខាងក្រោមនេះ ៖

ឯកតា: ពាន់រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | ឥណទានថ្មីមុននិយ័តកម្ម | និយ័តកម្ម | | ឥណទានថ្មីក្រោយនិយ័តកម្ម |
|---|---|---|---|---|---|---|---|---|
| | | | | | | កើន | ថយ | |
| | | | **និយ័តកម្មផ្ទៃក្នុងជំពូក ៦២** | | | **898.440** | **898.440** | |
| 62 | 622 | 6221 | សោហ៊ុយទទួលភ្ញៀវជាតិ | 150.000 | 120.000 | - | 24.000 | 96.000 |
| 62 | 622 | 6222 | សោហ៊ុយទទួលភ្ញៀវបរទេស | 300.000 | 150.000 | - | 86.000 | 64.000 |
| 62 | 622 | 6223 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 1.000.000 | 700.000 | - | 501.050 | 198.950 |
| 62 | 622 | 6224 | សោហ៊ុយពិធីបុណ្យ | 100.000 | 81.000 | - | 70 | 80.930 |
| 62 | 622 | 6225 | ចំណាយសម្រាប់វត្ថុអនុស្សាវរីយ៍ក្នុង និងក្រៅប្រទេស | 77.000 | 37.000 | - | 37.000 | - |
| 62 | 625 | 6251 | សោហ៊ុយដឹកជញ្ជូនក្រៅប្រទេស | 140.000 | 180.000 | - | 132.630 | 47.370 |
| 62 | 625 | 6252 | សោហ៊ុយបេសកកម្មក្រៅប្រទេស | 90.000 | 103.500 | - | 41.050 | 62.450 |
| 62 | 625 | 6253 | សោហ៊ុយស្នាក់នៅក្រៅប្រទេស | 110.000 | 181.000 | - | 76.640 | 104.360 |
| 62 | 624 | 6241 | សោហ៊ុយដឹកជញ្ជូនក្នុងប្រទេស | 873.000 | 1.086.820 | 141.123 | - | 1.227.943 |
| 62 | 624 | 6242 | សោហ៊ុយបេសកកម្មក្នុងប្រទេស | 560.000 | 707.266 | 90.561 | - | 797.827 |
| 62 | 624 | 6243 | សោហ៊ុយស្នាក់នៅក្នុងប្រទេស | 3.100.000 | 3.973.414 | 666.756 | - | 4.640.170 |
| | | | **និយ័តកម្មផ្ទៃក្នុងជំពូក ៦៥** | | | **8.100** | **8.100** | |
| 65 | 657 | 6572 | ឱសថ | 30.000 | 30.000 | - | 8.100 | 21.900 |
| 65 | 657 | 6578 | ផ្សេងៗ | 200.000 | 200.000 | 8.100 | - | 208.100 |

**ប្រការ២:** ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ពន្លឺ មុនីរ័ត្ន

**ចម្លងជូន**

- អគ្គនាយកដ្ឋានរតនាគារជាតិ
- នាយកដ្ឋានហិរញ្ញកិច្ច
  " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១១៣១ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០១៣

# ប្រកាស
## ស្តីពីការធ្វើនិយ័តកម្មឥណទានថវិកា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣, ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០, ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក, ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និង កែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៦ អនក្រ.បក, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ ជាតិ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញប្រកាសលេខ ១០១៨ សហវ.ប្រក, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ ផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនី សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣
- យោងលិខិតលេខ ៨១៣ សនថហ, ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៣ របស់ក្រសួងសុខាភិបាល

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ៍ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ ១** :ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិកា( មិនមែនកម្មវិធី ) របស់ក្រសួងសុខាភិបាល សម្រាប់ការគ្រប់គ្រងថវិកាឆ្នាំ ២០១៣ នូវការធ្វើនិយ័តកម្មឥណទានថវិកា ដូចមានបញ្ជាក់ខាងក្រោម ៖

ឯកតា:ពាន់រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ឥណទានឆ្នាំ២០១៣ | ឥណទានបច្ចុប្បន្ន | និយ័តកម្ម | | ឥណទានថ្មីក្រោយនិយ័តកម្ម |
|---|---|---|---|---|---|---|---|---|
| | | | | | | កើន | ថយ | |
| | | | **និយ័តកម្មផ្ទៃក្នុងជំពូក 64** | **-** | **-** | **160.000** | **160.000** | **-** |
| 64 | 641 | 6414 | ប្រាក់បំណាច់រដ្ឋមន្ត្រី រដ្ឋលេខាធិការ.... | 572.400 | 572.400 | 50.000 | - | 622.400 |
| 64 | 642 | 6422 | ប្រាក់បំណាច់មុខងារ | 6.575.900 | 6.575.900 | - | 110.000 | 6.465.900 |
| 64 | 642 | 6423 | ប្រាក់បំណាច់ម៉ោងបន្ថែម | 784.700 | 784.700 | - | 50.000 | 734.700 |
| 64 | 642 | 6427 | ប្រាក់បំណាច់ទទួលខុសត្រូវ | 831.000 | 831.000 | 50.000 | - | 881.000 |
| 64 | 645 | 6454 | ឧបត្ថម្ភនិវត្តជន | 334.200 | 334.200 | 60.000 | - | 394.200 |

**ប្រការ ២** :ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន-ព័ន្ធមុនីរ័ត្ន**

<u>ចម្លងជូន</u>
- អគ្គនាយកដ្ឋានរតនាគារជាតិ
- នាយកដ្ឋានហិរញ្ញកិច្ច
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

* MINISTRY OF ECONOMY AND FINANCE *
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១១៧២ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០១៣

# ប្រកាស
## ស្តីពីការបន្ថែមឥណទានថវិកា
## ជូនក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣, ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០, ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក, ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និង កែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៦ អនក្រ.បក, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ ជាតិ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញប្រកាសលេខ ១០១៨ សហវ.ប្រក, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ ផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនី សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣
- យោងលិខិតលេខ ៦៦៣ សនថហ, ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៣ របស់ក្រសួងសុខាភិបាល

## សម្រេច

**ប្រការ១**:ដោយអនុលោមទៅតាមមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ត្រូវបានអនុញ្ញាតឱ្យបំពេញបន្ថែមឥណទានថវិកា ជំពូក ៦៤ (បន្ទុកបុគ្គលិក) ចំនួន ១ ៦៥៩ ៥០០ ០០០រៀល(មួយពាន់ប្រាំមួយរយហាសិបប្រាំបួនលាន ប្រាំរយពាន់រៀលគត់) ជូនក្រសួងសុខាភិបាល សម្រាប់ការគ្រប់គ្រងថវិកាឆ្នាំ ២០១៣ ដូចមានបញ្ជាក់ខាងក្រោម ៖

ឯកតា:ពាន់រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ឥណទានឆ្នាំ ២០១៣ | ឥណទាន បច្ចុប្បន្ន | ឥណទាន បំពេញបន្ថែម | ឥណទាន ថ្មីក្រោយ បន្ថែម |
|---|---|---|---|---|---|---|---|
| | | | បន្ថែមឥណទានជំពូក ៦៤ | | | **1.659.500** | |
| 64 | 643 | 6433 | រង្វាន់ | 183.700 | 183.700 | 1.659.500 | 1.843.200 |

**ប្រការ២**:ឥណទានថវិកាដែលបានបន្ថែមក្នុងប្រការ ១ ខាងលើនេះ ត្រូវបានអនុញ្ញាតឱ្យបំពេញបន្ថែមទៅក្នុងសៀវភៅថវិការបស់ក្រសួងសុខាភិបាល ដើម្បីបំពេញបន្ថែមលើខ្ទង់ប្រាក់រង្វាន់ដែលខ្វះក្នុងឆ្នាំ ២០១៣ ។

**ប្រការ៣**:ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន-ព័ន្ធមុនីរ័ត្ន**

ចម្លងជូន
- អគ្គនាយកដ្ឋានរតនាគារជាតិ
- នាយកដ្ឋានហិរញ្ញកិច្ច
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១១៣៣ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០១៣

# ប្រកាស
## ស្តីពីការបន្ថែមឥណទានថវិកាជូនក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣, ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០, ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក, ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និង អនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និង កែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៦ អនក្រ.បក, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញប្រកាសលេខ ១០១៨ សហវ.ប្រក, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ ផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនី សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣
- យោងលិខិតលេខ ៨១២ សនថហ, ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៣ របស់ក្រសួងសុខាភិបាល

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ័ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

**សម្រេច**

**ប្រការ១**:ដោយអនុលោមទៅតាមមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ត្រូវបានអនុញ្ញាតឱ្យបំពេញបន្ថែមឥណទានថវិកាជំពូក៦៤(បន្ទុកបុគ្គលិក)ចំនួន៣៥៩ ០០០ ០០០រៀល(បីរយហាសិបប្រាំបួនលានរៀលគត់) ជូនក្រសួងសុខាភិបាល សម្រាប់ការគ្រប់គ្រងថវិកាឆ្នាំ២០១៣ ដូចមានបញ្ជាក់ខាងក្រោម ៖

ឯកតា:ពាន់រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ឥណទានឆ្នាំ ២០១៣ | ឥណទាន បច្ចុប្បន្ន | ឥណទាន បំពេញបន្ថែម | ឥណទាន ថ្មីក្រោយ បន្ថែម |
|---|---|---|---|---|---|---|---|
| | | | បន្ថែមជំពូក៦៤ | | | **359.000** | |
| 64 | 642 | 6421 | បៀវត្សមូលដ្ឋាន | 19.349.300 | 19.349.300 | 359.000 | 19.708.300 |

**ប្រការ២**:ឥណទានថវិកាដែលបានបន្ថែមក្នុងប្រការ ១ ខាងលើនេះ ត្រូវបានអនុញ្ញាតឱ្យបំពេញបន្ថែមទៅក្នុងសៀវភៅថវិការបស់ក្រសួងសុខាភិបាល ដើម្បីបំពេញបន្ថែមលើខ្វះបៀវត្សមូលដ្ឋានដែលខ្វះក្នុងឆ្នាំ ២០១៣ ។

**ប្រការ៣**:ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន_ព័ន្ធមុនីរ័ត្ន**

<u>ចម្លងជូន</u>
- អគ្គនាយកដ្ឋានរតនាគារជាតិ
- នាយកដ្ឋានហិរញ្ញកិច្ច
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១១៣៤ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣

# ប្រកាស
## ស្តីពីការធ្វើនិយ័តកម្មឥណទានថវិកា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០,ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី ១៨ ខែ វិច្ឆកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ២០ អនក្រ.បក, ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក, ចុះថ្ងៃទី១៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៦ អនក្រ.បក, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញប្រកាសលេខ ១០១៤ សហវ.ប្រក, ចុះថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការ បែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូក តាមគណនីនិងអនុគណនី សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- យោងលិខិតលេខ ២១២៨ អយក.កឆ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៣ របស់មន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ឆ្នាំង និងចំណារបញ្ជូនលេខ ៥៤ អយក.ប,ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៣ របស់ក្រសួងអប់រំយុវជន និងកីឡា

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨

## សម្រេច

**ប្រការ១**: ត្រូវបានប្រតិបត្តិនៅក្នុងវង្ង់ថវិការបស់មន្ទីរអប់រំយុវជននិងកីឡាខេត្តកំពង់ឆ្នាំងនៃក្រសួងអប់រំយុវជននិងកីឡា សម្រាប់ការគ្រប់គ្រងថវិកាឆ្នាំ២០១៣ នូវការធ្វើនិយ័តកម្មឥណទានថវិកាដូចមានបញ្ជាក់ខាងក្រោម៖

ឯកតា : ពាន់រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ឥណទានដើមឆ្នាំ | ឥណទានបច្ចុប្បន្ន | និយ័តកម្ម | | ឥណទានថ្មីក្រោយនិយ័តកម្ម |
|---|---|---|---|---|---|---|---|---|
| | | | | | | កើន | ថយ | |
| | | | និយ័តកម្មផ្ទៃក្នុងជំពូក៦៤ | | | 660.000 | 660.000 | |
| 64 | 642 | 6421 | បៀវត្សមូលដ្ឋាន | 15.257.500 | 15.257.500 | 660.000 | - | 15.917.500 |
| 64 | 642 | 6422 | ប្រាក់បំណាច់មុខងារ | 6.709.100 | 6.709.100 | - | 660.000 | 6.049.100 |

**ប្រការ២**: ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ឯកឧត្តមអភិបាល ខេត្តកំពង់ឆ្នាំង ជាអ្នកទទួលបន្ទុកអនុវត្ត ប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**

ចម្លងជូន
- អគ្គនាយកដ្ឋានរតនាគារជាតិ
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកំពង់ឆ្នាំង
- រតនាគារខេត្តកំពង់ឆ្នាំង
"ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១១៣៥ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០១៣

# ប្រកាស
# ស្តីពីការធ្វើនិយ័តកម្មឥណទានថវិកា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣, ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ,ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៦ អនក្រ.បក, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១៣
- បានឃើញប្រកាសលេខ ១០១៨ សហវ.ប្រក, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ ផ្ទៃក្នុងជំពូក តាមគណនី អនុគណនី សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១៣
- យោងលិខិតលេខ ២១៣/០១៣ មកន សណ ចុះថ្ងៃទី ០៤ ខែ កក្កដាឆ្នាំ២០១៣ របស់មន្ទីរ កិច្ចការនារី ខេត្តរតនគិរី និងចំណារបញ្ជូនលេខ ៣៥០ កកន/ហផ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៣ របស់ក្រសួងកិច្ចការនារី

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ័ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១:** ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិការបស់មន្ទីរកិច្ចការនារីខេត្តរតនគិរី នៃក្រសួងកិច្ចការនារី សម្រាប់ការគ្រប់គ្រងថវិកាឆ្នាំ២០១៣ នូវការធ្វើនិយ័តកម្មឥណទានថវិកាដូចមានបញ្ជាក់ខាងក្រោម ៖

ឯកតា : ពាន់រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ឥណទានដើមឆ្នាំ | ឥណទានបច្ចុប្បន្ន | និយ័តកម្ម | | ឥណទានថ្មីក្រោយនិយ័តកម្ម |
|---|---|---|---|---|---|---|---|---|
| | | | | | | កើន | ថយ | |
| | | | ការធ្វើនិយ័តកម្មផ្ទៃក្នុងជំពូក ៦៤ | | | **40.506** | **40.506** | |
| 64 | 642 | 6421 | បៀវត្សមូលដ្ឋាន | 92.000 | 92.000 | 40.506 | - | 132.506 |
| 64 | 642 | 6422 | ប្រាក់បំណាច់មុខងារ | 35.000 | 35.000 | - | 11.000 | 24.000 |
| 64 | 642 | 6426 | ប្រាក់បំណាច់តំបន់ | 900 | 900 | - | 372 | 528 |
| 64 | 644 | 6441 | បៀវត្សមូលដ្ឋានបុគ្គលិកជាប់កិច្ចសន្យា | 29.000 | 29.000 | - | 15.560 | 13.440 |
| 64 | 644 | 6443 | បៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត | 11.500 | 11.500 | - | 2.712 | 8.788 |
| 64 | 645 | 6451 | ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ | 2.500 | 2.500 | - | 1.278 | 1.222 |
| | | | - កូនមានអាយុតិចជាង១៥ឆ្នាំ | 2.000 | 2.000 | - | 850 | 1.150 |
| | | | - ប្រាក់បំណាច់អ្នកក្នុងបន្ទុក | 500 | 500 | - | 428 | 72 |
| 64 | 645 | 6452 | មន្ត្រីមានជំងឺ និងឧបត្ថម្ភអ្នកសម្រាលកូន | 30.000 | 30.000 | - | 5.584 | 24.416 |
| 64 | 645 | 6454 | ឧបត្ថម្ភនិវត្តជន | 4.000 | 4.000 | - | 4.000 | - |

**ប្រការ២:** លោកជំទាវរដ្ឋមន្ត្រីក្រសួងកិច្ចការនារីឯកឧត្តមអភិបាលខេត្តរតនគិរីជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពី ថ្ងៃចុះហត្ថលេខាតទៅ

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន_ព័ន្ធមុនីរ័ត្ន

ចម្លងជូន
- អគ្គនាយកដ្ឋានរតនាគារជាតិ
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តរតនគិរី
- រតនាគារខេត្តរតនគិរី
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១១៣៦ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ២០១៣

# ប្រកាស
## ស្តីពីការធ្វើនិយ័តកម្មឥណទានថវិកា

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣,ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤,ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨,ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦, ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១២១២/ ០១០,ចុះថ្ងៃទី២៦ ខែ ធ្នូ ឆ្នាំ ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣

-បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក,ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ និងអនុក្រឹត្យពាក់ព័ន្ធស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ១៣៤ អនក្រ.បក, ចុះថ្ងៃទី១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ. បក,ចុះថ្ងៃទី១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក,ចុះថ្ងៃទី២៩ ខែ មិនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងការសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ២៧៦ អនក្រ.បក,ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣

-បានឃើញប្រកាសលេខ ១០១៨ សហវ.ប្រក,ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ ផ្ទៃក្នុងជំពូក តាមគណនី អនុគណនី សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣

-យោងតាមសំណើលេខ២៥១សហវ,ចុះថ្ងៃទី១៦ ខែ សីហា ឆ្នាំ ២០១៣ របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបង និងយោងចំណារបញ្ជូនមកលេខ១៣៥០សភិ.ចុះថ្ងៃទី២២ ខែ សីហា ឆ្នាំ ២០១៣ របស់អភិបាលខេត្តបាត់ដំបង

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១**.ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិការបស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបង នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ នូវការធ្វើនិយ័តកម្មឥណទានថវិកាដូចមានបញ្ជាក់ខាងក្រោម ៖

(ឯកតា: ពាន់រៀល)

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៣ | ឥណទានថ្មីមុននិយ័តកម្ម | និយ័តកម្ម | | ឥណទានថ្មីក្រោយនិយ័តកម្ម |
|---|---|---|---|---|---|---|---|---|
| | | | | | | កើន | ថយ | |
| | | | និយ័តកម្មផ្ទៃក្នុងជំពូក62 | | | 12.152 | 12.152 | |
| 62 | 624 | 6241 | សោហ៊ុយដឹកជញ្ជូន | 6.000 | 6.000 | 1.964 | - | 7.964 |
| | | 6243 | សោហ៊ុយស្នាក់នៅ | 21.200 | 21.200 | 10.188 | - | 31.388 |
| | | 6242 | សោហ៊ុយបេសកកម្ម | 17.000 | 17.000 | - | 12.152 | 4.848 |
| | | | និយ័តកម្មផ្ទៃក្នុងជំពូក64 | | | 2.000 | 2.000 | |
| 64 | 642 | 6422 | ប្រាក់បំណាច់មុខងារ | 27.900 | 27.900 | 2.000 | - | 29.900 |
| | 645 | 6453 | មរណភាព | 3.000 | 3.000 | - | 2.000 | 1.000 |

**ប្រការ២**.ឯកឧត្តមអភិបាលខេត្តបាត់ដំបង ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត អ៊ុន_ព័ន្ធមុនីរ័ត្ន

**ចម្លងជូន**

-អគ្គនាយកដ្ឋានរតនាគារជាតិ

-រតនាគារ ខេត្តបាត់ដំបង

"ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៩២៨/ឧរ.ក.អ.ក/ប្រក

# ប្រកាសបង្កើតរោងចក្រ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញលិខិតលេខ១៧៨៣/១៣ គ.ស.ព ចុះថ្ងៃទី០៩.០៨.២០១៣ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន តៃគី (ខេមបូឌា) ចុះថ្ងៃទី០២.០៩.២០១៣

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន តៃគី (ខេមបូឌា) (TAIKI (CAMBODIA) CO., LTD.) តំណាងដោយ លោក KOJI NAKAMURA សញ្ជាតិជប៉ុន អាយុ៥១ឆ្នាំ កាន់លិខិតឆ្លងដែនលេខ TK7096926 ចុះថ្ងៃទី២៩.០៥.២០១២ មានអាសយដ្ឋានបច្ចុប្បន្ន៖23-20-104, Higashiyamacyo, Ashiya City, Hyogo Pref., 659-0091, Japan ធ្វើការបង្កើត រោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្ភារៈសំអាង | ២០២៣ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣

**ផ្លាកឈ្មោះរោងចក្រ ៖** *" រោងចក្រផលិតគ្រឿងសំអាង តែគី (ខេមបូឌា) "*

**ទីតាំងរោងចក្រ៖** *" តំបន់សេដ្ឋកិច្ចពិសេស កំពង់ផែក្រុងព្រះសីហនុ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។ ៕

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៣

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**រដ្ឋលេខាធិការ**

**ឡាយ ណាវីន**

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រាជកិច្ច

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-សាលាខេត្តព្រះសីហនុ

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៤ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ :

# ប្រកាសបង្កើតរោងចក្រ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ២១៩៣/១៣ គ.វ.ក ចុះថ្ងៃទី១៨.០៩.២០១៣ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ជុងយៀក ថេកស្ទាយ ហ្វេកធើរី លីមីធីត ចុះថ្ងៃទី០៩.០៩.២០១៣

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ជុងយៀក ថេកស្ទាយ ហ្វេកធើរី លីមីធីត (CHUNG YICK TEXTILE FACTORY LIMITED) តំណាងដោយ កញ្ញា SUNG LOK YI សញ្ជាតិចិន អាយុ២១ឆ្នាំ កាន់លិខិតឆ្លងដែនលេខKJ0190598 ចុះថ្ងៃទី១០.១២.២០១២ មានអាសយដ្ឋានបច្ចុប្បន្នៈ House No.28, Cedar Drive Redhill Peninsula Tai Tam, Hong Kong. ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោមៈ

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ១- សម្លៀកបំពាក់ (កាត់ដេរ), ស្រោមដៃ, កន្សែង, មួក | ១៤១០ |
| ២- សម្លៀកបំពាក់ (ចាក់, ប៉ាក់) | ១៤៣០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ . ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax : 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** " *រោងចក្រកាត់ដេរ-ចាក់ និងប៉ាក់សម្លៀកបំពាក់ ផុងយៀក ថេកស្តាយ ហ្វេកថើរី ពីរីធីត* "

**ទីតាំងរោងចក្រ៖** " *ភូមិសាមគ្គី ឃុំស្វាយរៀង ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង* "

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានផនតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តស្វាយរៀង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែ ១១ ឆ្នាំ២០១៣

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**រដ្ឋលេខាធិការ**

**ឡាយ ណាទីន**

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តស្វាយរៀង
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ: [illegible]

# ប្រកាសបង្កើតរោងចក្រ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ១៩៩២/១៣ គ.វ.ក ចុះថ្ងៃទី២៩.០៨.២០១៣ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន វ៉ានធីជ រីវើរ ថេកស្ពាន ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន វ៉ានធីជ រីវើរ ថេកស្ពាយ (VANTAGE RIVER TEXTILES CO., LTD.) តំណាងដោយ លោក CHIANG, KUO-YU សញ្ជាតិចិន (តៃវ៉ាន់) អាយុ៦២ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 306937005 ចុះថ្ងៃទី២១.០២.២០១៣ មានអាសយដ្ឋានបច្ចុប្បន្ន៖ 6F-4, N0.118, Min Sheng E.Rd., Taipei, Taiwan. R.O.C ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
| --- | --- |
| សម្លៀកបំពាក់ | ១៤១០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax : 855-23-428263

**- ផ្លាកឈ្មោះរោងចក្រ ៖** *" រោងចក្រកាត់ដេរសម្លៀកបំពាក់វ៉ានធីជ រីវើរ ថេកស្តាយ "*
**- ទីតាំងរោងចក្រ ៖** *" ភូមិ៥ សង្កាត់៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាម អាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ ១១ ឆ្នាំ២០១៣

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**រដ្ឋលេខាធិការ**

**ឡាយ ណាទីន**

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តព្រះសីហនុ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤,, "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ: ៩៧៣ ឧរថ-កន-ប្រក

# ប្រកាសបង្កើតរោងចក្រ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ៩២៥/១២ ម.ត.ស.ព ចុះថ្ងៃទី១៩.១១.២០១២ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន អង្គរ សាញ ឌីវេឡុបមេន (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី០៥.១១.២០១៣

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន អង្គរ សាញ ឌីវេឡុបមេន (ខេមបូឌា) ខូអិលធីឌី (ANGKOR SHINE DEVELOPMENT (CAMBODIA) CO., LTD.) តំណាងដោយ លោក LE TRUNG TAN សញ្ជាតិវៀតណាម អាយុ៤៩ឆ្នាំ កាន់លិខិតឆ្លងដែនលេខB6829490 ចុះថ្ងៃទី១២.០៧.២០១២ មានអាសយដ្ឋានបច្ចុប្បន្ន៖ No.2B, Alley 38, Lane 340, Road Dong Ho, P8, Quan Tan Binh, TP. HCM, Vietnam. ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ១- សម្លៀកបំពាក់ | ១៤១០ |
| ២- តម្កក់ព្យួរសម្លៀកបំពាក់ | ២៥៩៩ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax : 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** *" រោងចក្រកាត់ដេរសម្លៀកបំពាក់ និងផលិតតម្កក់ព្យួរសម្លៀកបំពាក់ អង្គរសោភា "*

**ទីតាំងរោងចក្រ៖** *" ផ្លូវជាតិលេខ១ ភូមិព្រៃផ្ដៅ សង្កាត់ប្រកម្ទេស ក្រុងបាវិត ខេត្តស្វាយរៀង "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្ដីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្ដីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្ដីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។/.

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៩៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។/.

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាម មាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តស្វាយរៀង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**រដ្ឋលេខាធិការ**

**ឡាយ ណាវីន**

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តស្វាយរៀង
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៩៧៤ ឧស្ម.កសឧ.ប្រក

# ប្រកាសបង្កើតរោងចក្រ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញលិខិតលេខ២២៨៨/១៣គ.វ.ក ចុះថ្ងៃទី២៧.០៩.២០១៣ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ឃ្យូ & ភែក ផេភើរ ខាថិន ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៣

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ឃ្យូ & ភែក ផេភើរ ខាថិន (Q & PACK PAPER CARTONS CO., LTD.) តំណាងដោយ លោក ស៊ីន ចេងឃាង សញ្ជាតិខ្មែរ អាយុ៣៨ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ 010469168 ចុះថ្ងៃទី២១.០៦.២០១០ មានអាសយដ្ឋានបច្ចុប្បន្ន៖ ផ្ទះលេខ ១១១ ផ្លូវ១៩១ ភូមិ១០ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| កេសកាតុង | ១៧០២ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax : 855-23-428263

**-ផ្លាកឈ្មោះរោងចក្រ ៖** *"រោងចក្រផលិតកេសកាតុង យូ & កែក ផេភើរ ខាថិន"*

**-ទីតាំងរោងចក្រ ៖** *"ផ្លូវជាតិលេខ២ ភូមិព្រៃកគាគង់៣ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ"*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាម អាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៥៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែ ១១ ឆ្នាំ២០១៣

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**រដ្ឋលេខាធិការ**

**ឡាយ ណាវីន**

**ចម្លងជូន:**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -រាជកិច្ច
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងបរិស្ថាន
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -សាលារាជធានីភ្នំពេញ

"ដើម្បីជូនជ្រាប"
- -ដូចប្រការ១៤,, "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ